فَقَالَ (عَلَيْهِ السَّلاَمُ): «نَحْنُ الْبُيُوتُ الَّتِي أَمَرَ اللَّهُ بِهَا أَنْ تُؤْتَى مِنْ أَبْوَابِهَا، نَحْنُ بَابُ اللَّهِ وَ بُيُوتُهُ الَّتِي يُؤْتَى مِنْهَا، فَمَنْ بَايَعَنَا وَ أَقَرَّ بِوَلاَيَتِنَا فَقَدْ أَتَى الْبُيُوتَ مِنْ أَبْوَابِهَا، وَ مَنْ خَالَفَنَا وَ فَضَّلَ عَلَيْنَا غَيْرَنَا فَقَدْ أَتَى الْبُيُوتَ مِنْ ظُهُورِهَا». (الإحتجاج:227)**

អាមីរុល-មុមីនីន(صلوات الله عليه والسلام)មានវចនៈថា៖ «យើង(عليهم السلام)គឺផ្ទះដែលអល់ឡោះ(عز وجل)បញ្ជាឲ្យអស់លោកចូលមកតាមទ្វារវានោះ ។ ដូច្នេះអ្នកណាបានសច្ចាស្មោះស្ម័គ្រចំពោះយើង(عليهم السلام) បានទទួលស្គាល់រឿងយ៉ាស្ុ យើង(عليهم السلام) អ្នកនោះបានចូលមកតាមទ្វារផ្ទះនោះ ។ អ្នកណាប្រឆាំងយើង(عليهم السلام) ស្មោះស្ម័គ្រអ្នកផ្សេងពីយើង(عليهم السلام) អ្នកនោះចូលផ្ទះតាមខាងក្រោយ ។» (الاحتجاج: 227)

***

الْعَيَّاشِيُّ: عَنْ سَعْدٍ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ)، قَالَ: سَأَلْتُهُ عَنْ هَذِهِ الْآيَةِ: "وَ لَيْسَ الْبِرُّ بِأَنْ تَأْتُوا الْبُيُوتَ مِنْ ظُهُورِهٰا وَ لٰكِنَّ الْبِرَّ مَنِ اتَّقىٰ وَ أْتُوا الْبُيُوتَ مِنْ أَبْوٰابِهٰا". فَقَالَ: «آلُ مُحَمَّدٍ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) أَبْوَابُ اللَّهِ وَ سَبِيلُهُ، وَ الدُّعَاةُ إِلَى الْجَنَّةِ، وَ الْقَادَةُ إِلَيْهَا، وَ الْأَدِلاَّءُ عَلَيْهَا إِلَى يَوْمِ الْقِيَامَةِ». (تفسير العيّاشي 86/ 210: 1)**

អាល់-អ្ហ៊ីយ៉ាស្ុីបានថ្លែងតមកពី អាប៊ូ យ៉ាកុ៊ហ្ជារ(صلوات الله عليه والسلام) ថាខ្ញុំបានសួរព្រះអង្គ(صلوات الله عليه والسلام)អំពីអាយ៉ាស្ុនេះ *[២:១៨៩] មិនត្រឹមត្រូវទេដែលពួកអ្នកចូលផ្ទះតាមខាងក្រោយនោះ តែត្រឹមត្រូវគឺបុគ្គលដែលខ្លាចក្រែង[អល់ឡោះ]ហ៊ានដោយជឿសិប់ចិត្ត ។ ចូរពួកអ្នកចូលផ្ទះតាមទ្វារ (គឺដោយស្របច្បាប់)* ។ ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈថា៖ «ព្រះរាជបុត្ររាជនត្តា(عليهم السلام)របស់មូហ៊ាំម៉ាដ(صلى الله عليه وآله وسلم)ជាទ្វារបស់អល់ឡោះ(عز وجل) ជាព្រះមាគ៌ាព្រះអង្គ(عز وجل) ជាអ្នកអញ្ជើញគេទៅរកឋានសួគ៌ ជាអ្នកដឹកនាំទៅរកឋានសួគ៌នោះ ហើយជាអ្នកបង្ហាញផ្លូវទៅរកឋានសួគ៌នោះរហូតដល់ថ្ងៃជំនុំជម្រះ ។» (تفسير العيّاشي 1: 86/ 210)

وَقَٰتِلُواْ فِي سَبِيلِ ٱللَّهِ ٱلَّذِينَ يُقَٰتِلُونَكُمۡ وَلَا تَعۡتَدُوٓاْۚ إِنَّ ٱللَّهَ لَا يُحِبُّ ٱلۡمُعۡتَدِينَ ١٩٠

១៩០. ចូរពួកអ្នកប្រយុទ្ធលើមាគ៌ាអល់ឡោះ(عز وجل) ទល់នឹងបណ្ដាអ្នក[បង្ក្រាវិនាស]ដែលប្រយុទ្ធទល់នឹងពួកអ្នក តែចូរពួកអ្នកកុំបំពាន ។ អល់ឡោះ(عز وجل)មិនសព្វព្រះរាជហឫទ័យអ្នកបំពានទេ ។

وَٱقۡتُلُوهُمۡ حَيۡثُ ثَقِفۡتُمُوهُمۡ وَأَخۡرِجُوهُم مِّنۡ حَيۡثُ أَخۡرَجُوكُمۡۚ وَٱلۡفِتۡنَةُ أَشَدُّ مِنَ ٱلۡقَتۡلِۚ وَلَا تُقَٰتِلُوهُمۡ عِندَ ٱلۡمَسۡجِدِ ٱلۡحَرَامِ حَتَّىٰ يُقَٰتِلُوكُمۡ فِيهِۖ فَإِن قَٰتَلُوكُمۡ فَٱقۡتُلُوهُمۡۗ كَذَٰلِكَ جَزَآءُ ٱلۡكَٰفِرِينَ ١٩١

១៩១. ចូរពួកអ្នកសម្លាប់ពួកនោះ [ដែលជាជននាំឲ្យវិនាសដែលប្រយុទ្ធទល់នឹងពួកអ្នក] មិនថាឡើយ ពួកអ្នកជួបប្រទះពួកគេនៅទីណាក៏ដោយ ។ ចូរពួកអ្នកបណ្តេញពួកគេចេញពីទីកន្លែងណា ដែលពួកគេបានបណ្តេញពួកអ្នកចេញ ។ ចលាចល (គឺការញ៉ាំងឲ្យមនុស្សបែរចេញពីជំនឿលើ អល់ឡោះហ្គ៉ា និងការញ៉ាំងឲ្យធ្វើអំពើលាមក) អ្ប្រិយលើសឃាតកម្ម ។ ចូរពួកអ្នកកុំប្រយុទ្ធទល់ នឹងពួកទាំងនោះឯព្រះវិហារពិសិដ្ឋឡើយ (គឺកាក្ប៉ាស៊ូ) រ៉ៀរលែងតែពួកអស់នោះប្រយុទ្ធទល់ នឹងពួកអ្នកឯទីនោះ[ជាមុន] ។ បើពួកគេប្រយុទ្ធទល់នឹងពួកអ្នក[នៅទីនោះ] ចូរពួកអ្នកសម្លាប់ ពួកគេចុះ នេះគឺការតបស្នងរបស់បណ្តាជនបដិសេធសទ្ធា ។

فَإِنِ ٱنتَهَوۡاْ فَإِنَّ ٱللَّهَ غَفُورٞ رَّحِيمٞ ١٩٢

១៩២. បើពួកគេឈប់ (គឺលែងប្រយុទ្ធ) អល់ឡោះហ្គ៉ាអត់ឱន ព្រះអង្គប្រកបដោយព្រះមេត្តាករុណា ប្រណី ។

وَقَٰتِلُوهُمۡ حَتَّىٰ لَا تَكُونَ فِتۡنَةٞ وَيَكُونَ ٱلدِّينُ لِلَّهِۖ فَإِنِ ٱنتَهَوۡاْ فَلَا عُدۡوَٰنَ إِلَّا عَلَى ٱلظَّٰلِمِينَ ١٩٣

១៩៣. ចូរពួកអ្នកប្រយុទ្ធទល់នឹងពួកគេ[ដែលជាជននាំឲ្យវិនាស]ទាល់តែអស់ចលាចល ហើយ សាសនាទៅជារបស់អល់ឡោះហ្គ៉ាតែមួយគត់ ។ បើពួកគេឈប់ មិនអនុញ្ញាតឲ្យបង្ករឿងអរិភាព ទេ រ៉ៀរលែងតែទល់នឹងពួកទុច្ចរិត ។

អធិប្បាយអាយ៉ាស៊ុ ១៩០-១៩៣

أَبُو عَلِيٍّ الطَّبْرِسِيُّ: وَ قَاتِلُوهُمْ حَتَّى لاَ تَكُونَ فِتْنَةٌ أَيْ شِرْكٌ. قَالَ: وَ هُوَ الْمَرْوِيُّ عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ). (مجمع البيان 2:513)**

អាប៊ូ អ្ហ:លី អាល់-ត្ប:ារ:ស៊ីបានថ្លែងថា *[២:១៩៣] ចូរពួកអ្នកប្រយុទ្ធទល់នឹងពួកគេទាល់តែអស់ ចលាចល ។* ព្រះអង្គ صلوات الله عليه والسلام (គឺអ៊ីមុាំ صلوات الله عليه والسلام) មានវចន:ថា: «[ចលាចល] គឺបទពហុទេពនិយម (شرك) ។ គេ បានតំណាលតមកពីអាប៊ូ យ៉ាក្ភ:ហ្វារ صلوات الله عليه والسلام ។» (مجمع البيان 2: 513)

***

الْعَيَّاشِيُّ: عَنِ الْحَسَنِ بَيَّاعِ الْهَرَوِيِّ، يَرْفَعُهُ، عَنْ أَحَدِهِمَا (عَلَيْهِمَا السَّلاَمُ)، فِي قَوْلِهِ: "فَلاَ عُدْوَانَ إِلاَّ عَلَى الظَّالِمِينَ". قَالَ: «إِلاَّ عَلَى ذُرِّيَّةِ قَتَلَةِ الْحُسَيْنِ (عَلَيْهِ السَّلاَمُ)». (تفسير العيّاشي 86/ 214: 1)**

អាល់-អ៊ៃយ៉ាស៊ីបានតំណាលតមកពីអាល់-ហ្ហាសាន់ បាយ៉ាអ៊ុ អាល់-ហ្ហារី ថាគេបានសួរអ៊ីមុាំមួយអង្គ صلوات الله عليه والسلام (គឺអ៊ីមុាំទី៥ صلوات الله عليه والسلام ឬ ទី៦ صلوات الله عليه والسلام) អំពីព្រះបន្ទូលអល់ឡោះហ្គ៉ា عز وجل *[២:១៩៣] មិនអនុញ្ញាតឲ្យបង្ករឿង*

អរិភាពទេ ក្រៅលែងតែទល់នឹងពួកទុច្ចរិត ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ «លើកលែងតែទល់នឹងបណ្តាកូនចៅរបស់បណ្តាអ្នកដែលបានសម្លាប់អាល់-ហ្ស៊ូសែន صلوات الله عليه والسلام ។» (تفسير العيّاشي 1: 86/ 214)

***

عَنْ إِبْرَاهِيمَ، قَالَ: أَخْبَرَنِي مَنْ رَوَاهُ عَنْ أَحَدِهِمَا (عَلَيْهِمَا السَّلاَمُ)، قَالَ: قُلْتُ: "فَلاَ عُدْوَانَ إِلاَّ عَلَى الظَّالِمِينَ"؟ قَالَ: «لاَ يَعْتَدِي اللَّهُ سُبْحَانَهُ عَلَى أَحَدٍ، إِلاَّ عَلَى نَسْلِ قَتَلَةِ الْحُسَيْنِ (عَلَيْهِ السَّلاَمُ)». (تفسير العيّاشي 87/ 216: 1)**

អ៊ីបរ៉ហ៊ីមបានតំណាលថា គេបានតំណាលប្រាប់ខ្ញុំតមកពីម្នាក់ដែលបានថ្លែងតមកពីអ៊ីមុាំមួយអង្គ صلوات الله عليه والسلام (គឺអ៊ីមុាំទី៥ صلوات الله عليه والسلام ឬ ទី៦ صلوات الله عليه والسلام) ថាខ្ញុំបានសួរថា៖ *«[២:១៩៣] មិនអនុញ្ញាតឲ្យបង្ករឿងអរិភាពទេ ក្រៅលែងតែទល់នឹងពួកទុច្ចរិត* [មានន័យថាអ្វី] ?» ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ «អល់ឡោះហ្វ៉ា សូមថ្វាយសេចក្តីរុងរឿងចំពោះអង្គ عز وجل មិនវាយប្រហារអ្នកណាផ្សេងពីបណ្តាកូនចៅជំនាន់ក្រោយៗរបស់បណ្តាអ្នកសម្លាប់អាល់-ហ្ស៊ូសែន صلوات الله عليه والسلام ទេ ។» (تفسير العيّاشي 1: 87/ 216)

ٱلشَّهۡرُ ٱلۡحَرَامُ بِٱلشَّهۡرِ ٱلۡحَرَامِ وَٱلۡحُرُمَٰتُ قِصَاصٞۚ فَمَنِ ٱعۡتَدَىٰ عَلَيۡكُمۡ فَٱعۡتَدُواْ عَلَيۡهِ بِمِثۡلِ مَا ٱعۡتَدَىٰ عَلَيۡكُمۡۚ وَٱتَّقُواْ ٱللَّهَ وَٱعۡلَمُوٓاْ أَنَّ ٱللَّهَ مَعَ ٱلۡمُتَّقِينَ ١٩٤

១៩៤. បូជនីយខែសងបូជនីយខែ ។ បូជនីយវត្ថុទាំងអស់[ដែលត្រូវគេឈ្លានពាន]ទាមទារការទូទាត់ធួននឹងកំហុស ។ បុគ្គលណាប្រព្រឹត្តិដោយឈ្លានពានមកលើពួកអ្នក ចូរពួកអ្នកវាយប្រហារសងអ្នកនោះវិញ(គឺតតបវិញ) ស្មើនឹងបទឈ្លានពានដែលបានប្រព្រឹត្តមកលើពួកអ្នក ។ ចូរពួកអ្នកខ្លាចក្រែង អល់ឡោះហ្វ៉ា ចូរដឹងថាអល់ឡោះហ្វ៉ានៅខាងបណ្តាអ្នកខ្លាចក្រែង [ដែលស្តាប់បង្គាប់ឡោះហ្វ៉ា] ។

អធិប្បាយអាយ៉ាស់ ១៩៤

مُحَمَّدُ بْنُ يَعْقُوبَ: عَلِيُّ بْنُ إِبْرَاهِيمَ، عَنْ أَبِيهِ، وَ مُحَمَّدُ بْنُ إِسْمَاعِيلَ، عَنِ الْفَضْلِ بْنِ شَاذَانَ، جَمِيعاً، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، قَالَ: سَأَلْتُ أَبَا عَبْدِ اللَّهِ (عليه السلام) عَنْ رَجُلٍ قَتَلَ رَجُلًا فِي الْحِلِّ، ثُمَّ دَخَلَ الْحَرَمَ. فَقَالَ: «لَا يُقْتَلُ وَ لَا يُطْعَمُ وَ لَا يُسْقَى وَ لَا يُبَايَعُ وَ لَا يُؤْوَى حَتَّى يَخْرُجَ مِنَ الْحَرَمِ فَيُقَامَ عَلَيْهِ الْحَدُّ».

[...] មូអ្ការីយ៉ាស់ ប៊ិន អ្ការ៉ាមបានតំណាលថាខ្ញុំបានសួរអាប៊ូ អ្ការ៉ាប ឌ្ហុលឡោះហ្វ៉ា صلوات الله عليه والسلام អំពីបុរសម្នាក់ដែលបានសម្លាប់បុរសម្នាក់នៅកន្លែងមិនហាមឃាត់ (គឺក្រៅបូជនីយស្ថាន) ហើយចូលទៅក្នុងបូជនីយស្ថាន ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ «មិនសម្លាប់អ្នកនោះទេ មិនផ្តល់អាហារឲ្យទេ មិនផ្តល់ទឹកឲ្យទេ មិនជួញដូរឬជួយការពារទេ មិនផ្តល់ជម្រកឲ្យទេ លុះត្រាតែអ្នកនោះចេញពីបូជនីយស្ថាន ទើបអាចផ្តន្ទាទោសអ្នកនោះតាមច្បាប់បាន ។»

قَالَ: قُلْتُ فَمَا تَقُولُ فِي رَجُلٍ قَتَلَ فِي الْحَرَمِ أَوْ سَرَقَ؟ قَالَ: «يُقَامُ عَلَيْهِ الْحَدُّ فِي الْحَرَمِ، صَاغِراً إِنَّهُ لَمْ يَرَ لِلْحَرَمِ حُرْمَةً، وَ قَدْ قَالَ اللَّهُ عَزَّ وَ جَلَّ: فَمَنِ اعْتَدى عَلَيْكُمْ فَاعْتَدُوا عَلَيْهِ بِمِثْلِ مَا اعْتَدى عَلَيْكُمْ - فَقَالَ -: هَذَا هُوَ فِي الْحَرَمِ - فَقَالَ - فَلا عُدْوانَ

إِلَّا عَلَى الظَّالِمِينَ».

ខ្ញុំបានសួរថា: «តើព្រះអង្គ صلوات الله عليه والسلام យល់ឃើញយ៉ាងណាអំពីបុរសដែលសម្លាប់ឬលួចនៅក្នុងបូជនីយស្ថាន ?» ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា: «ចូរផ្ដន្ទាទោសអ្នកនោះតាមច្បាប់នៅក្នុងបូជនីយស្ថាន ព្រោះអ្នកនោះមិនគោរពបូជនីយស្ថានទេ ហើយអល់ឡោះហ្ស៊ូ ﷻ មានព្រះបន្ទូលថា: *[២:១៩៤] បុគ្គលណាប្រព្រឹត្ដិដោយឈ្លានពានមកលើពួកអ្នក ចូរពួកអ្នកវាយប្រហារសងអ្នកនោះវិញ (គឺតតបវិញ) ស្មើនឹងបទឈ្លានពានដែលបានប្រព្រឹត្ដមកលើពួកអ្នក ។* នេះគឺក្នុងបរិវេណបូជនីយស្ថាន អល់ឡោះហ្ស៊ូ ﷻ មានព្រះបន្ទូលថា: *[២:១៩៣] មិនអនុញ្ញាតឲ្យបង្ករឿងអរិភាពទេ ក្ដៅតែងតែទល់នឹងពួកទុច្ចរិត ។»*
(الكافي 4 : 227 / 4)

وَأَنفِقُواْ فِي سَبِيلِ ٱللَّهِ وَلَا تُلۡقُواْ بِأَيۡدِيكُمۡ إِلَى ٱلتَّهۡلُكَةِۚ وَأَحۡسِنُوٓاْۚ إِنَّ ٱللَّهَ يُحِبُّ ٱلۡمُحۡسِنِينَ ١٩٥

១៩៥. ចូរពួកអ្នកចាយវាយលើមាគ៌ាអល់ឡោះហ្ស៊ូ ។ ពួកអ្នកចូរកុំបោលសម្រុកទៅរកវិនាសកម្មដោយដៃឯងឡើយ ។ ចូរពួកអ្នកធ្វើអំពើល្អ[រកគ្នា] ។ អល់ឡោះហ្ស៊ូសព្វព្រះរាជហឫទ័យបណ្ដាអ្នកធ្វើអំពើល្អ ។

អធិប្បាយអាយ៉ាស់ ១៩៥

مُحَمَّدُ بْنُ يَعْقُوبَ: عِدَّةٌ مِنْ أَصْحَابِنَا، عَنْ أَحْمَدَ بْنِ مُحَمَّدٍ، وَ سَهْلِ بْنِ زِيَادٍ، عَنِ ابْنِ مَحْبُوبٍ، عَنْ يُونُسَ بْنِ يَعْقُوبَ، عَنْ حَمَّادِ بْنِ وَاقِدٍ اللَّحَّامِ، عَنْ أَبِي عَبْدِ اللَّهِ (عليه السلام)، قَالَ: «لَوْ أَنَّ رَجُلًا أَنْفَقَ مَا فِي يَدَيْهِ فِي سَبِيلٍ مِنْ سَبِيلِ اللَّهِ مَا كَانَ أَحْسَنَ وَ لَا وُفِّقَ، أَ لَيْسَ يَقُولُ اللَّهُ تَعَالَى: وَ لا تُلْقُوا بِأَيْدِيكُمْ إِلَى التَّهْلُكَةِ وَ أَحْسِنُوا إِنَّ اللَّهَ يُحِبُّ الْمُحْسِنِينَ يَعْنِي الْمُقْتَصِدِينَ».

[...] ហ្ជាម៉ាដ្ដ៊ ប៊ិន វ៉ាគ្ដ៊ីដ្ដ អាល់-ឡាស្ស:ហ្ជ៊ាំបានតំណាលតមកពីអាប៊ូ អ្ចាប់ឌ្ឆុលឡោះហ្ស៊ូ صلوات الله عليه والسلام ដែលមានវចន:ថា: «បើមនុស្សចាយវាយអ្វីដែលនៅក្នុងដៃខ្លួនទៅលើមាគ៌ាអល់ឡោះហ្ស៊ូ ﷻ មិនមានអ្វីប្រសើរនិងសក្ដិសមលើសនេះទេ ។ អល់ឡោះហ្ស៊ូ تعالى មិនមានព្រះបន្ទូលទេថា *[២:១៩៥] ចូរពួកអ្នកចាយវាយលើមាគ៌ាអល់ឡោះហ្ស៊ូ ។ ពួកអ្នកចូរកុំបោលសម្រុកទៅរកវិនាសកម្មដោយដៃឯងឡើយ ។ ចូរពួកអ្នកធ្វើអំពើល្អ[រកគ្នា] ។ អល់ឡោះហ្ស៊ូសព្វព្រះរាជហឫទ័យបណ្ដាអ្នកធ្វើអំពើល្អ* ? មានន័យថា ចូរប្រុងប្រយ័ត (ក្នុងការចាយវាយ) ។» (الكافي 4: 53 / 7)

وَأَتِمُّواْ ٱلۡحَجَّ وَٱلۡعُمۡرَةَ لِلَّهِۚ فَإِنۡ أُحۡصِرۡتُمۡ فَمَا ٱسۡتَيۡسَرَ مِنَ ٱلۡهَدۡيِۖ وَلَا تَحۡلِقُواْ رُءُوسَكُمۡ حَتَّىٰ يَبۡلُغَ ٱلۡهَدۡيُ مَحِلَّهُۥۚ فَمَن كَانَ مِنكُم مَّرِيضًا أَوۡ بِهِۦٓ أَذٗى مِّن رَّأۡسِهِۦ فَفِدۡيَةٞ مِّن صِيَامٍ أَوۡ صَدَقَةٍ أَوۡ نُسُكٖۚ فَإِذَآ أَمِنتُمۡ فَمَن تَمَتَّعَ بِٱلۡعُمۡرَةِ إِلَى ٱلۡحَجِّ فَمَا ٱسۡتَيۡسَرَ مِنَ ٱلۡهَدۡيِۚ فَمَن لَّمۡ يَجِدۡ فَصِيَامُ ثَلَٰثَةِ أَيَّامٖ فِي ٱلۡحَجِّ وَسَبۡعَةٍ إِذَا رَجَعۡتُمۡۗ تِلۡكَ عَشَرَةٞ كَامِلَةٞۗ ذَٰلِكَ لِمَن لَّمۡ يَكُنۡ أَهۡلُهُۥ حَاضِرِي ٱلۡمَسۡجِدِ ٱلۡحَرَامِۚ وَٱتَّقُواْ ٱللَّهَ وَٱعۡلَمُوٓاْ أَنَّ ٱللَّهَ شَدِيدُ ٱلۡعِقَابِ ١٩٦

១៩៦. ចូរពួកអ្នកបំពេញពិធីបូជនីយេសចរក៍ (គឺពិធីហ្ជាជ) និងអ៊ុមរ៉ះតុ៌ដើម្បីអល់ឡោះហ្ជ៌ ។ បើពួកអ្នកត្រូវខកខាន ចូរពួកអ្នកទូទាត់សងដោយបូជាអ្វីមួយដែលអាចធ្វើបាន (គឺសំឡែះសត្វមួយ) ។ ចូរពួកអ្នកកុំអាលកោរសក់ កាលណាតង្វាយ (គឺសត្វដែលយកមកសំឡែះ) ពុំទាន់បានទៅដល់កន្លែងវាទេ ។ បើអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកឈឺ ឬមានការឈឺថ្កាត់លើក្បាល[ហើយចាំបាច់ត្រូវកោរសក់មុនពេល] អ្នកនោះត្រូវទូទាត់សងដោយកាន់សីលត្រណមអាហារ (៣ថ្ងៃ) ឬដោយដាក់អំណោយទាន ឬដោយធ្វើពលីទានសំឡែះសត្ว ។ ពេលពួកអ្នកផុតភ័យ អ្នកណាមួយដែលបំពេញពិធីអ៊ុមរ៉ះតុ៌ភ្ជាប់ជាមួយពិធីហ្ជាជ ចូរអ្នកនោះបូជាអ្វីមួយ (គឺដោយសំឡែះសត្ว) ដែលអាចធ្វើបាន (គឺតាមសមត្ថភាព ដូចជាសំឡែះពពែមួយក្បាលជាដើម) ។ តែបើអ្នកណារកមិនបាន (គឺពុំអាចធ្វើពលីទានបានដោយខ្វះលទ្ធភាព) ចូរអ្នកនោះទូទាត់សងដោយកាន់សីលត្រណមអាហារបីថ្ងៃក្នុងអំឡុងពេលធ្វើពិធីហ្ជាជ និងប្រាំពីរថ្ងៃទៀតពេលត្រឡប់មកផ្ទះខ្លួនវិញ សរុបទាំងអស់គឺដប់ថ្ងៃ ។ នេះ[ជាកម្រិត]សម្រាប់បុគ្គលណាដែលគ្រួសាររបស់ខ្លួនមិនអាស្រ័យនៅក្បែរបូជនីយវិហារទេ (គឺម៉ាក់កាស៊ុ) ។ ចូរពួកអ្នកខ្លាចក្រែងអល់ឡោះហ្ជ៌ ។ ចូរដឹងថាអល់ឡោះហ្ជ៌តបស្នងវិញតឹងរ៉ឹងណាស់ ។

អធិប្បាយអាយ៉ាស៊ុ ១៩៦

مُحَمَّدُ بْنُ يَعْقُوبَ: عَلِيُّ بْنُ إِبْرَاهِيمَ، عَنْ أَبِيهِ، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ عُمَرَ بْنِ أُذَيْنَةَ، قَالَ: كَتَبْتُ إِلَى أَبِي عَبْدِ اللَّهِ (عليه السلام) بِمَسَائِلَ بَعْضُهَا مَعَ ابْنِ بُكَيْرٍ، وَ بَعْضُهَا مَعَ أَبِي الْعَبَّاسِ، فَجَاءَ الْجَوَابُ بِإِمْلَائِهِ: «سَأَلْتَ عَنْ قَوْلِ اللَّهِ عَزَّ وَ جَلَّ: وَ لِلَّهِ عَلَى النَّاسِ حِجُّ الْبَيْتِ مَنِ اسْتَطاعَ إِلَيْهِ سَبِيلًا يَعْنِي بِهِ الْحَجَّ وَ الْعُمْرَةَ جَمِيعاً، لِأَنَّهُمَا مَفْرُوضَانِ».

[...] ម្ហ៊ីម៉ារ ប៊ិន អ្ហ្ស៊ីណាស៊ុ បានតំណាលថាខ្ញុំបានសរសេរសំបុត្រទៅអាប៊ូ អ្ហ្ស៊ាប់ឌុលឡោះហ្ជ៌ صلوات الله عليه والسلام សួរព្រះអង្គ صلوات الله عليه والسلام សំណួរមួយចំនួនជាមួយអ៊ីបនូ ប៊ូកៃរ៌ សួរសំណួរមួយចំនួនទៀតជាមួយអាប៊ូ អាល់-អ្ហ្ស៊ាប់បាស់ ។ ព្រះអង្គ صلوات الله عليه បានសរសេរតបមកវិញថា៖ «លោកបានសួរអំពីព្រះបន្ទូលអល់ឡោះហ្ជ៌ عز وجل *[៣:៩៧] ទៅបំពេញពិធីហ្ជាជ្ជ*ឯ*ព្រះមហាគ្រឹះ ដើម្បីអល់ឡោះហ្ជ៌ ជាបញ្ញត្តិលើមនុស្សរាល់គ្នាដែលអាចមានផ្លូវទៅទីនោះបាន* មានន័យថាពិធីហ្ជាជ្ជនិងអ៊ុមរ៉ះតុ៌ជាមួយគ្នា ពីព្រោះទាំងពីនេះជាប្រការចាំបាច់ (គឺជាហ្វារ១ឌ្ជ) ។»

وَ سَأَلْتُهُ عَنْ قَوْلِ اللَّهِ عَزَّ وَ جَلَّ: وَ أَتِمُّوا الْحَجَّ وَ الْعُمْرَةَ لِلَّهِ قَالَ: «يَعْنِي بِتَمَامِهِمَا: أَدَاءَهُمَا، وَ اتِّقَاءَ مَا يَتَّقِي الْمُحْرِمُ فِيهِمَا».

ខ្ញុំបានសួរព្រះអង្គ صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ្ជ៌ عز وجل *[២:១៩៦] ចូរពួកអ្នកបំពេញពិធីបូជនីយេសចរក៍ (គឺពិធីហ្ជាជ) និងអ៊ុមរ៉ះតុ៌ ។* ព្រះអង្គ صلوات الله عليه មានវចន:ថា៖ «"បំណេញ" មានន័យថាប្រតិបត្តិករណីយកិច្ចនេះដោយចៀសវាងអ្វីដែលគេហាមចំពោះបុគ្គលគ្រងអ៊ុះហ្ជ៌រ៉ម ។

وَ سَأَلْتُهُ عَنْ قَوْلِهِ تَعَالَى: الْحَجِّ الْأَكْبَرِ مَا يَعْنِي بِالْحَجِّ الْأَكْبَرِ؟ فَقَالَ: «الْحَجُّ الْأَكْبَرُ الْوُقُوفُ بِعَرَفَةَ وَ رَمْيُ الْجِمَارِ وَ الْحَجُّ الْأَصْغَرُ: الْعُمْرَةُ».

ខ្ញុំបានសួរព្រះអង្គ صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ្ការ៉ាតាឡា تعالى *[៩:៣] ពិធីហ្ចាច្ចធំ ។* តើពិធីហ្ចាច្ចធំមានន័យថាអ្វី ? ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ «ពិធីហ្ចាច្ចធំ (الْحَجُّ الْأَكْبَرُ) គឺការឈប់សម្រាកនៅឯអ្ការ៉ហ្ការ៉ាសុ ការចោលដុំថ្មទៅលើអាល់-យ៉ាម៉ារ ។ ឯពិធីហ្ចាច្ចតូច គឺអ៊ុមរ៉ោះតុ៌ ។» (الكافي 4 : 1 / 264)

***

ابْنُ بَابَوَيْهِ، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ الْحَسَنِ بْنِ أَحْمَدَ بْنِ الْوَلِيدِ (رَضِيَ اللَّهُ عَنْهُ)، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ الْحَسَنِ الصَّفَّارُ، عَنِ الْعَبَّاسِ بْنِ مَعْرُوفٍ، عَنْ عَلِيِّ بْنِ مَهْزِيَارَ، عَنِ الْحُسَيْنِ بْنِ سَعِيدٍ، عَنِ ابْنِ أَبِي عُمَيْرٍ، وَ حَمَّادٍ، وَ صَفْوَانَ بْنِ يَحْيَى، وَ فَضَالَةَ بْنِ أَيُّوبَ، عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «الْعُمْرَةُ وَاجِبَةٌ عَلَى الْخَلْقِ بِمَنْزِلَةِ الْحَجِّ، مَنِ اسْتَطَاعَ، لِأَنَّ اللَّهَ عَزَّ وَ جَلَّ يَقُولُ: "وَ أَتِمُّوا الْحَجَّ وَ الْعُمْرَةَ لِلَّهِ" وَ إِنَّمَا نَزَلَتِ الْعُمْرَةُ بِالْمَدِينَةِ، وَ أَفْضَلُ الْعُمْرَةِ عُمْرَةُ رَجَبٍ». (علل الشرائع: 408/ 1)**

[...] ម៉ូអ្ការ៉ីយ៉ាសុ ប៊ិន អ្ការ៉ម៉ារបានតំណាលតមកពីអាប៊ូ អ្ការ៉ប់ឌ្ឍុលឡោះ صلوات الله عليه والسلام ដែលមានវចនៈថា៖ «អ៊ុមរ៉ោះតុ៌ជាប្រការចាំបាច់ (ជាហ្ការ៉ជ្ជ) លើសត្វលោកគ្រប់រូប ដូចពិធីហ្ចាច្ចដែរ សម្រាប់អ្នកណាដែលមានលទ្ធភាព ព្រោះអល់ឡោះហ្ការ៉ជ្ជ ﷻ មានព្រះបន្ទូលថា៖ *[២:១៩៦] ចូរពួកអ្នកបំពេញពិធីបូជនីយេសចរក៍ (គឺពិធីហ្ចាច្ច) និងអ៊ុមរ៉ោះតុ៌ដើម្បីអល់ឡោះហ្ការ៉ ។* អាយ៉ាសុ់នេះត្រូវបើកឲ្យដឹងនៅឯម៉ាឌ្ឌីណាសុ់ស្តីអំពីអ៊ុមរ៉ោះតុ៌ ហើយអ៊ុមរ៉ោះតុ៌ល្អជាងគេគឺអ៊ុមរ៉ោះតុ៌ខែរ៉ាយ៉ាប់ ។» (علل الشرائع: 408 / 1)

***

عَنْهُ: عَنْ عَلِيٍّ، عَنْ أَبِيهِ، عَنْ حَمَّادٍ، عَنْ حَرِيزٍ، عَمَّنْ أَخْبَرَهُ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «مَرَّ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) عَلَى كَعْبِ بْنِ عُجْرَةَ وَ الْقَمْلُ يَتَنَاثَرُ مِنْ رَأْسِهِ وَ هُوَ مُحْرِمٌ، فَقَالَ لَهُ: أَ تُؤْذِيكَ هَوَامُّكَ؟ فَقَالَ: نَعَمْ، فَأُنْزِلَتْ هَذِهِ الْآيَةُ: "فَمَنْ كَانَ مِنْكُمْ مَرِيضاً أَوْ بِهِ أَذىً مِنْ رَأْسِهِ فَفِدْيَةٌ مِنْ صِيامٍ أَوْ صَدَقَةٍ أَوْ نُسُكٍ" فَأَمَرَهُ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) أَنْ يَحْلِقَ، وَ جَعَلَ الصِّيَامَ ثَلاَثَةَ أَيَّامٍ، وَ الصَّدَقَةَ عَلَى سِتَّةِ مَسَاكِينَ، لِكُلِّ مِسْكِينٍ مُدَّانِ، وَ النُّسُكَ شَاةً». (الكافي 358/ 2: 4)**

[...] ហ្ការ៉ីសុបានតំណាលតមកពីម្នាក់ដែលបានតំណាលប្រាប់លោកតមកពីអាប៊ូ អ្ការ៉ប់ឌ្ឍុលឡោះ صلوات الله عليه والسلام ដែលមានវចនៈថា៖ «រ៉ាស៊ូលុលឡោះ صلى الله عليه وآله وسلم ហ្ការ៉ បានជួបកាអ្ការ៉ប់ ប៊ិន អ្ការ៉ជ្ជ៉ោះតុ៌ ។ គាត់កើតចៃពេញក្បាលហើយគាត់គ្រងអ៊ុះហ្ការ៉រ៉ម ។ រ៉ាស៊ូលុលឡោះ صلى الله عليه وآله وسلم ហ្ការ៉ បានសួរគាត់ថា៖ "ចៃមិនធ្វើឲ្យលោកឈឺចាប់ទេ ?" គាត់បានទូលថា៖ "វាធ្វើឲ្យទូលបង្គំឈឺ ។" អាយ៉ាសុ់នេះក៏ត្រូវបើកឲ្យដឹងឡើងថា៖ *[២:១៩៦] បើអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកឈឺ ឬមានការឈឺថ្កាត់លើក្បាល អ្នកនោះត្រូវទូទាត់សងដោយកាន់សីលត្រណមអាហារ ឬដោយដាក់អំណោយទាន ឬដោយធ្វើពលីទានសំឡេះសត្ត ។* រ៉ាស៊ូលុលឡោះ صلى الله عليه وآله وسلم ក៏បានដាក់បញ្ជាឲ្យគាត់កោរក្បាល ឲ្យកាន់សីលត្រណមអាហារបីថ្ងៃ ឲ្យដាក់ទានដល់មនុស្សក្រប្រាំមួយនាក់ ម្នាក់ៗឲ្យពីរមុដ្ឋ (គឺ ៧៥០ ក្រាមពីរដង) ហើយឲ្យសំឡេះកូនចៀមមួយ ។» (الكافي 4 : 2 / 358)

***

وَ عَنْهُ: بِإِسْنَادِهِ عَنْ مُوسَى بْنِ الْقَاسِمِ، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ حَمَّادٍ، عَنِ الْحَلَبِيِّ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «دَخَلَتِ الْعُمْرَةُ فِي الْحَجِّ إِلَى يَوْمِ الْقِيَامَةِ، لِأَنَّ اللَّهَ تَعَالَى يَقُولُ: "فَمَنْ تَمَتَّعَ بِالْعُمْرَةِ إِلَى الْحَجِّ فَمَا اسْتَيْسَرَ مِنَ الْهَدْيِ" فَلَيْسَ لِأَحَدٍ إِلاَّ أَنْ يَتَمَتَّعَ، لِأَنَّ اللَّهَ أَنْزَلَ ذَلِكَ فِي كِتَابِهِ، وَ جَرَتْ بِهِ السُّنَّةُ مِنْ رَسُولِ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)». (التهذيب 25/ 75: 5)**

[...] អាល់-ហ្ជាល់ប៊ីបានតំណាលតមកពីអាប៊ូ អ្ហ៊ាប់ឌ្ឈុលឡោះហ្ហ៊ា صلوات الله عليه والسلام ដែលមានវចន:ថា: «អ៊ុ៊ូមរ៉ះតុ៌ត្រូវ រាប់បញ្ចូលក្នុងពិធីហ្ជាជ្ជរហ្ជតដល់ថ្ងៃជំនុំជម្រះ ព្រោះអល់ឡោះហ្ហ៊ា عز وجل មានព្រះបន្ទូលថា: *[២:១៩៦] អ្នកណាមួយដែលបំពេញពិធីអ៊ុ៊ូមរ៉ះតុ៌ភ្ជាប់ជាមួយពិធីហ្ជាជ្ជ ចូរអ្នកនោះបូជាអ្វីមួយដែលអាចធ្វើបាន ។* ដូច្នេះនេះគឺសម្រាប់អ្នកណាដែលធ្វើអ៊ុ៊ូមរ៉ះតុ៌ តាម៉ាត់ទុ៌អ (គឺធ្វើអ៊ុ៊ូមរ៉ះតុ៌ភ្ជាប់ជាមួយពីធីហ្ជាជ្ជ) ព្រោះ អល់ឡោះហ្ហ៊ា عز وجل បានបើកឲ្យដឹងរឿងនេះនៅក្នុងព្រះគម្ពីរព្រះអង្គ عز وجل ហើយមានតរៀងមកដល់ស្ហ៊ីណាតុ៌ រ៉ស៊ូលុលឡោះហ្ហ៊ា صلى الله عليه وآله ។» (التهذيب 5 : 25 / 75)

***

عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِهِ: "فَمَنْ تَمَتَّعَ بِالْعُمْرَةِ إِلَى الْحَجِّ فَمَا اسْتَيْسَرَ مِنَ الْهَدْيِ". قَالَ: «لِيَكُنْ كَبْشاً سَمِيناً، فَإِنْ لَمْ يَجِدْ فَعِجْلاً مِنَ الْبَقَرِ، وَ الْكَبْشُ أَفْضَلُ، فَإِنْ لَمْ يَجِدْ فَمَوْجُوءاً مِنَ الضَّأْنِ، وَ إِلاَّ مَا اسْتَيْسَرَ مِنَ الْهَدْيِ شَاةٌ». (تفسير العيّاشي 91/ 234: 1)**

មូអ្ហ៊ាវីយ៉ាស ប៊ិន អ្ហ៊ាម៉ារបានតំណាលតមកពីអាប៊ូ អ្ហ៊ាប់ឌ្ឈុលឡោះហ្ហ៊ា صلوات الله عليه والسلام ដែលមានវចន:អំពីព្រះបន្ទូល អល់ឡោះហ្ហ៊ា عز وجل *[២:១៩៦] អ្នកណាមួយដែលបំពេញពិធីអ៊ុ៊ូមរ៉ះតុ៌ភ្ជាប់ជាមួយពិធីហ្ជាជ្ជ ចូរអ្នកនោះបូជាអ្វីមួយដែលអាចធ្វើបាន* ថា: «ចូរយកបាចៀមធាត់ បើរកមិនបានទេ ចូរយកកូនគោ ។ តែល្អឲ្យយកបា ចៀម បើរកមិនបានទេចូរយកកូនចៀមឈ្មោល ពុំនោះទេឲ្យយកអ្វីដែលងាយរកបានជាងកូនចៀមដើម្បី បូជា ។» (تفسير العيّاشي 1 : 91 / 235)

***

عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِ اللَّهِ: "فَصِيَامُ ثَلاَثَةِ أَيَّامٍ فِي الْحَجِّ وَ سَبْعَةٍ إِذَا رَجَعْتُمْ" قَالَ: «إِذَا رَجَعْتَ إِلَى أَهْلِكَ». (تفسير العيّاشيّ 92/ 239: 1)**

មូអ្ហ៊ាវីយ៉ាស ប៊ិន អ្ហ៊ាម៉ារបានតំណាលតមកពីអាប៊ូ អ្ហ៊ាប់ឌ្ឈុលឡោះហ្ហ៊ា صلوات الله عليه والسلام ដែលមានវចន:អំពីព្រះបន្ទូល អល់ឡោះហ្ហ៊ា عز وجل *[២:១៩៦] កាន់សីលត្រណមអាហារបីថ្ងៃក្នុងអំឡុងពេលធ្វើពិធីហ្ជាជ្ជ និងប្រាំពីរថ្ងៃទៀត ពេលត្រឡប់មកផ្ទះខ្លួនវិញ* ថា: «ពេលលោកត្រឡប់មករកគ្រួសារលោកវិញ ។»
(تفسير العيّاشي 1 : 92 / 239)

***

وَ عَنْهُ: عَنْ عَلِيُّ بْنُ إِبْرَاهِيمَ، عَنْ أَبِيهِ، عَنْ حَمَّادِ بْنِ عِيسَى، عَنْ حَرِيزٍ، عَنْ أَبِي عَبْدِ اللَّهِ (عليه السلام)، فِي قَوْلِ اللَّهِ عَزَّ وَ جَلَّ: ذلِكَ لِمَنْ لَمْ يَكُنْ أَهْلُهُ حاضِرِي الْمَسْجِدِ الْحَرامِ. قَالَ: «مَنْ كَانَ مَنْزِلُهُ عَلَى ثَمَانِيَةَ عَشَرَ مِيلًا مِنْ بَيْنِ يَدَيْهَا، وَ ثَمَانِيَةَ عَشَرَ مِيلًا مِنْ خَلْفِهَا، وَ ثَمَانِيَةَ عَشَرَ مِيلًا عَنْ يَمِينِهَا، وَ ثَمَانِيَةَ عَشَرَ مِيلًا عَنْ يَسَارِهَا، فَلَا مُتْعَةَ لَهُ، مِثْلَ مَرٍّ وَ أَشْبَاهِهَا».

[...] ហ្ជារីស្ថបានតំណាលតមកពីអាប៊ូ អ្ហ៊ាប់ឌ្ឈុលឡោះហ្ហ៊ា صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ្ហ៊ា عز وجل *[២:១៩៦] នេះសម្រាប់បុគ្គលណាដែលគ្រួសាររបស់ខ្លួនមិនអាស្រ័យនៅក្បែរបូជនីយវិហារទេ ។* ព្រះអង្គ صلوات الله عليه والسلام មាន វចន:ថា: «អ្នកណាដែលមានផ្ទះនៅឆ្ងាយពីមុខខ្លួនដប់ប្រាំបីមៃល៍ (២៩ គីឡូម៉ែត្រ) ឆ្ងាយពីខាងក្រោយ ខ្លួនដប់ប្រាំបីមៃល៍ ឆ្ងាយពីខាងស្តាំខ្លួនដប់ប្រាំបីមៃល៍ ឆ្ងាយពីខាងឆ្វេងខ្លួនដប់ប្រាំបីមៃល៍ អ្នកនោះមិន ធ្វើអ៊ុ៊ូមរ៉ះតុ៌តភ្ជាប់នឹងពិធីហ្ជាជ្ជទេ (គឺអ៊ុ៊ូមរ៉ះតុ៌ តាម៉ាត់ទុ៌អ គឺធ្វើអ៊ុ៊ូមរ៉ះតុ៌ជាមួយពីធីហ្ជាជ្ជ) ដូចជារស់ នៅឯម៉ារ (ស្រុកមួយក្បែរម៉ាក់កាស៊ូ) និងកន្លែងស្រដៀងនេះដែរ ។» (الكافي 4: 3 /300)

***

وَ عَنْهُ: بِإِسْنَادِهِ عَنْ مُوسَى بْنِ الْقَاسِمِ، عَنْ عَلِيِّ بْنِ جَعْفَرٍ، قَالَ: قُلْتُ لِأَخِي مُوسَى بْنِ جَعْفَرٍ (عَلَيْهِ السَّلاَمُ): لِأَهْلِ مَكَّةَ أَنْ يَتَمَتَّعُوا بِالْعُمْرَةِ إِلَى الْحَجِّ؟ فَقَالَ: «لاَ يَصْلُحُ أَنْ يَتَمَتَّعُوا لِقَوْلِ اللَّهِ عَزَّ وَ جَلَّ: "ذٰلِكَ لِمَنْ لَمْ يَكُنْ أَهْلُهُ حَاضِرِي الْمَسْجِدِ الْحَرَامِ" ». (التهذيب 32/ 97: 5)**

[...] មូសា ប៊ិន អាល់-ក្ការ៉ាមបានតំណាលតមកពីអ៊ីលី កូនរបស់យ៉ាកុ៊ប ហ្ការ ﷺ ដែលបានថ្លែងថាខ្ញុំ បានសួរមូសា ﷺ ប៊ិន យ៉ាកុ៊ប ហ្ការ ﷺ ថា៖ «តើអ្នកស្រុកម៉ាក់កាសុ៌ត្រូវធ្វើអ៊ុ៌មរ៉ោះតុ៌គួបជាមួយពិធីហ្ជាជ្ជទេ ?» ព្រះអង្គ ﷺ មានវចន:ថា៖ «មិនត្រឹមត្រូវទេដែលពួកគេធ្វើអ៊ុ៌មរ៉ោះតុ៌គួបជាមួយពិធីហ្ជាជ្ជ នោះ ព្រោះអល់ឡោះហ្ជ៌ ﷻ មានព្រះបន្ទូលថា៖ *[២:១៩៦] នេះសម្រាប់បុគ្គលណាដែលគ្រួសាររបស់ខ្លួនមិនអាស្រ័យនៅក្បែរបូជនីយវិហារទេ ។»* (التهذيب 5 : 32 / 97)

***

عِدَّةٌ مِنْ أَصْحَابِنَا عَنْ سَهْلِ بْنِ زِيَادٍ عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ أَبِي نَصْرٍ عَنْ عَبْدِ الْكَرِيمِ بْنِ عَمْرٍو عَنْ سَعِيدٍ الْأَعْرَجِ عَنْ أَبِي عَبْدِ اللَّهِ (عليه السلام) قَالَ لَيْسَ لِأَهْلِ سَرِفٍ وَ لَا لِأَهْلِ مَرٍّ وَ لَا لِأَهْلِ مَكَّةَ مُتْعَةٌ يَقُولُ اللَّهُ عَزَّ وَ جَلَّ ذلِكَ لِمَنْ لَمْ يَكُنْ أَهْلُهُ حاضِرِي الْمَسْجِدِ الْحَرامِ .

[...] សាអ៊ីដ្ជ អាល់-អាក្ការ៉ជ្ជ៌បានតំណាលតមកពីអាប៊ូ អ៊ាប់ឌុលឡោះហ្ស៊ ﷺ ដែលមានវចន:ថា៖ «មិនមានតាម៉ាត់ទុ៌ម្ម៉ូ (គឺធ្វើអ៊ុ៌មរ៉ោះតុ៌គួបជាមួយពីធីហ្ជាជ្ជ) សម្រាប់អ្នកស្រុកសារីហ្ជ (ស្រុកមួយឆ្ងាយពីម៉ាក់កាសុ៌ ៦ ម៉ែស៍ គឺ ៩,៥ គីឡូម៉ែត្រ) សម្រាប់អ្នកស្រុកម៉ារ៍ (ស្រុកមួយនៅឯប្រជុំផ្លូវម៉ាក់កាសុ៌) និងសម្រាប់អ្នកស្រុកម៉ាក់កាសុ៌ ។ អល់ឡោះហ្ជ៌ ﷻ មានព្រះបន្ទូលថា៖ *[២:១៩៦] នេះសម្រាប់បុគ្គលណាដែលគ្រួសាររបស់ខ្លួនមិនអាស្រ័យនៅក្បែរបូជនីយវិហារទេ ។»* (الكافي 4 ខណ្ឌទី57 ហ្ជាឌ្ជីស្ស1)

ٱلْحَجُّ أَشْهُرٌ مَّعْلُومَٰتٌ ۚ فَمَن فَرَضَ فِيهِنَّ ٱلْحَجَّ فَلَا رَفَثَ وَلَا فُسُوقَ وَلَا جِدَالَ فِى ٱلْحَجِّ ۗ وَمَا تَفْعَلُوا۟ مِنْ خَيْرٍ يَعْلَمْهُ ٱللَّهُ ۗ وَتَزَوَّدُوا۟ فَإِنَّ خَيْرَ ٱلزَّادِ ٱلتَّقْوَىٰ ۚ وَٱتَّقُونِ يَٰٓأُو۟لِى ٱلْأَلْبَٰبِ ﴿١٩٧﴾

១៩៧. ពិធីហ្ជាជ្ជត្រូវធ្វើឡើងក្នុងខែដែលបានកំណត់ស្រេចមកហើយ (គឺខែស្ហាវ៉ាល់ ស៊ុលក្ហ៊ីអ៊ីដាសុ៌ និង ១០ ថ្ងៃដើមខែស៊ុលហ្ជ៊ីជ្ជយ៉ាសុ៌) ។ អ្នកណាមួយសម្រេចចិត្តបំពេញពិធីហ្ជាជ្ជក្នុងខែទាំងនេះ មិនអនុញ្ញាតឲ្យអ្នកនោះរួមបវេណី មិនឲ្យប្រព្រឹត្តអំពើអសីលធម៌ មិនឲ្យឈ្លោះវិវាទគ្នាក្នុងពេលកំពុងធ្វើពិធីហ្ជាជ្ជឡើយ ។ អំពើល្អប្រពៃដែលពួកអ្នកប្រព្រឹត្តនោះ អល់ឡោះហ្ស៊ ﷻ ទ្រង់ញាណ ។ ចូរពួកអ្នកត្រៀមស្បៀងទុក ស្បៀងដែលប្រសើរបំផុតគឺអធិមោក្ខ (គឺជឿអល់ឡោះហ្ស៊ ﷻ សប់ចិត្ត) ។ ពួកអ្នកចូរមានអធិមោក្ខចំពោះអញ (គឺខ្លាចក្រែងនិងជឿអញសប់ចិត្ត) ឱបណ្ដាអ្នកមានវិចារណញ្ញាណអើយ ។

អធិប្បាយអាយ៉ាសុ៌ ១៩៧

مُحَمَّدِ بْنِ يَعْقُوبَ: عِدَّةٌ مِنْ أَصْحَابِنَا، عَنْ سَهْلِ بْنِ زِيَادٍ، عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ أَبِي نَصْرٍ، عَنْ مُثَنًّى الْحَنَّاطِ، عَنْ زُرَارَةَ، عَنْ

أَبِي جَعْفَرٍ (عليه السلام) قَالَ: «الْحَجُّ أَشْهُرٌ مَعْلُوماتٌ: شَوَّالٌ، وَ ذُو الْقَعْدَةِ، وَ ذُو الْحِجَّةِ، لَيْسَ لِأَحَدٍ أَنْ يَحُجَّ فِيمَا سِوَاهُنَّ».

[...] ស្វ៊ោះតុ៉ បានតំណាមតមកពីអាប៊ូ យ៉ាកុ៉ហ្វារ صلوات الله عليه والسلام ដែលមានវចន:ថា: *«[២:១៩៧] ពិធីហ្ជាជ្ជត្រូវធ្វើឡើងក្នុងខែដែលបានកំណត់ស្រេចមកហើយ* គឺខែស្ហ៊ាវ៉ាល់ ខែស៊ុលក្ងុ៉ក្ដ៉ាសុ ខែស៊ុលហ្ហ៊ីជ្ជយ៉ាសុ ។ មិនឲ្យអ្នកណាមួយធ្វើពិធីហ្ជាជ្ជក្រៅពីខែទាំងនេះទេ ។» (الكافي 4 : 289 / 1)

***

و عنه: عَلِيُّ بْنُ إِبْرَاهِيمَ، عَنْ أَبِيهِ، وَ مُحَمَّدُ بْنِ إِسْمَاعِيلَ، عَنِ الْفَضْلِ بْنِ شَاذَانَ، جَمِيعاً، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عليه السلام)، فِي قَوْلِ اللَّهِ عَزَّ وَ جَلَّ: الْحَجُّ أَشْهُرٌ مَعْلُوماتٌ فَمَنْ فَرَضَ فِيهِنَّ الْحَجَّ: «وَ الْفَرْضُ: التَّلْبِيَةُ وَ الْإِشْعَارُ وَ التَّقْلِيدُ، فَأَيَّ ذَلِكَ فَعَلَ فَقَدْ فَرَضَ الْحَجَّ، وَ لَا يُفْرَضُ الْحَجُّ إِلَّا فِي هَذِهِ الشُّهُورِ الَّتِي قَالَ اللَّهُ عَزَّ وَ جَلَّ: الْحَجُّ أَشْهُرٌ مَعْلُوماتٌ: وَ هُوَ شَوَّالٌ وَ ذُو الْقَعْدَةِ، وَ ذُو الْحِجَّةِ».

[...] មូអ៊ុ៉រីយ៉ាសុ៉ ប៊ិន អ៊ុ៉ម៉ារ បានតំណាលតមកពីអាប៊ូ អ៊ុ៉ប់ឌុ្ឍលឡោះហ្ស៊ ដែលមានវចន:អំពីព្រះបន្ទូលអល់ឡោះហ្ស៊ ﷻ *[២:១៩៧] ពិធីហ្ជាជ្ជត្រូវធ្វើឡើងក្នុងខែដែលបានកំណត់ស្រេចមកហើយ ។ អ្នកណាមួយសម្រេចចិត្តបំពេញពិធីហ្ជាជ្ជក្នុងខែទាំងនេះ* ថា: «កាតព្វកិច្ច (ហ្ជ្ជ) គឺតាល់ប៊ីយ៉ាសុ៉, ដាក់សញ្ញាសំគាល់លើតង្វាយ (គឺសត្វដែលយកទៅបូជា) នាំសត្វតង្វាយ ។ បើបានធ្វើប្រការទាំងនេះហើយ គឺបានធ្វើតាមកាតព្វកិច្ចពិធីហ្ជាជ្ជហើយ ។ មិនធ្វើពិធីហ្ជាជ្ជក្រៅពីខែដែលអល់ឡោះហ្ស៊ ﷻ បានចែងទេ គឺ: *[២:១៩៧] ពិធីហ្ជាជ្ជត្រូវធ្វើឡើងក្នុងខែដែលបានកំណត់ស្រេចមកហើយ* នេះគឺខែស្ហ៊ាវ៉ាល់ ខែស៊ុលក្ងុ៉ក្ដ៉ាសុ និងខែស៊ុលហ្ហ៊ីជ្ជយ៉ាសុ៉ ។» (الكافي 4 : 289 / 2)

***

الشَّيْخُ: بِإِسْنَادِهِ عَنْ مُوسَى بْنِ الْقَاسِمِ، عَنْ عَلِيِّ بْنِ جَعْفَرٍ، قَالَ: سَأَلْتُ أَخِي مُوسَى (عَلَيْهِ السَّلَامُ) عَنِ الرَّفَثِ وَ الْفُسُوقِ وَ الْجِدَالِ مَا هُوَ، وَ مَا عَلَى مَنْ فَعَلَهُ؟ قَالَ: «الرَّفَثُ: جِمَاعُ النِّسَاءِ، وَ الْفُسُوقُ: اَلْكَذِبُ وَ الْمُفَاخَرَةُ، وَ الْجِدَالُ: قَوْلُ الرَّجُلِ: لاَ وَ اللَّهِ، وَ بَلَى وَ اللَّهِ. فَمَنْ رَفَثَ فَعَلَيْهِ بَدَنَةٌ يَنْحَرُهَا، وَ إِنْ لَمْ يَجِدْ فَشَاةٌ، وَ كَفَّارَةُ الْفُسُوقِ يَتَصَدَّقُ بِهِ إِذَا فَعَلَهُ وَ هُوَ مُحْرِمٌ». (التهذيب 297/ 1005: 5)**

អាល់-ស្ហ៊ៃខ៉ បានតំណាល យោលតាមបណ្ដាញព័ត៌លោក តមកពីមូសា ប៊ិន ក្ងុ៉ស៊ីម តមកពីអ៊ុ៉លី ប៊ិន យ៉ាកុ៉ហ្វារ صلوات الله عليه والسلام ថាខ្ញុំបានសួរមូសា صلوات الله عليه والسلام អំពីរួមបវេណី អំពើអសីលធម៌ និងការឈ្លោះវិវាទគ្នា ថាតើប្រការទាំងនេះគឺអ្វី តើអ្នកប្រព្រឹត្តប្រការទាំងនេះត្រូវពិន័យបែបណា ? ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា: «រួមបវេណីគឺរួមដំណេកជាមួយនារី ។ អំពើអសីលធម៌គឺនិយាយកុហកនិងនិយាយអួត ។ ឈ្លោះវិវាទគ្នាគឺសំដីរបស់បុគ្គល ដូចជា ថា: "ទេ សូមស្បថចំពោះអល់ឡោះហ្ស៊ ﷻ ។ មែន សូមស្បថចំពោះអល់ឡោះហ្ស៊ ﷻ ។" ដូច្នេះអ្នកណាបានរួមដំណេក ឲ្យអ្នកនោះបូជាអូដ្ឋមួយ បើរកមិនបានទេឲ្យបូជាកូនចៀម ។ ការលាងកំហុសរបស់បុគ្គលអសីលធម៌ គឺឲ្យដាក់ទានបើអ្នកនោះបានប្រព្រឹត្តអំពើនេះខណ:ដែលកំពុងគ្រងអ៊ុ៉ះហ្ស៊ារ៉ម ។» (التهذيب 5 : 297 / 1005)

لَيۡسَ عَلَيۡكُمۡ جُنَاحٌ أَن تَبۡتَغُواْ فَضۡلٗا مِّن رَّبِّكُمۡۚ فَإِذَآ أَفَضۡتُم مِّنۡ عَرَفَٰتٖ فَٱذۡكُرُواْ ٱللَّهَ عِندَ ٱلۡمَشۡعَرِ
ٱلۡحَرَامِۖ وَٱذۡكُرُوهُ كَمَا هَدَىٰكُمۡ وَإِن كُنتُم مِّن قَبۡلِهِۦ لَمِنَ ٱلضَّآلِّينَ ١٩٨

១៩៨. ពុំមានបាបលើពួកអ្នកទេ បើពួកអ្នកស្វែងរកព្រះករុណាប្រណីពីព្រះម្ចាស់ពួកអ្នក[ទាក់ទងនឹងជីវិតលោកនេះ] ។ ពេលពួកអ្នកចាកចេញពីអារ៉ហ្វាត់ ចូរពួកអ្នករលឹកដល់អល់ឡោះហ្វ៍ក្បែរបូជនីយស្ថាន ។ ចូរពួកអ្នករលឹកដល់ព្រះអង្គដែលព្រះអង្គបានដឹកនាំពួកអ្នក ថ្វីបើកាលពីមុននោះពួកអ្នកជាជនវង្វេង ។

អធិប្បាយអាយ៉ាស់ ១៩៨

الْعَيَّاشِيُّ: عَنْ عُمَرَ بْنِ يَزِيدَ بَيَّاعِ السَّابِرِيِّ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِ اللَّهِ: "لَيْسَ عَلَيْكُمْ جُناحٌ أَنْ تَبْتَغُوا فَضْلاً مِنْ رَبِّكُمْ": «يَعْنِي الرِّزْقَ، إِذَا أَحَلَّ الرَّجُلُ مِنْ إِحْرَامِهِ وَ قَضَى نُسُكَهُ، فَلْيَشْتَرِ وَ لْيَبِعْ فِي الْمَوْسِمِ». (تفسير العيّاشي 96/ 262: 1)**

អាល់-អៃយ៉ាស៊ីបានតំណាលតមកពីអ៊ុម៉ារ ប៊ិន យ៉ាស៊ីដ បាយ៉ាអ៍ អាល់-សាប៊ីរី តមកពីអាប៊ូអាប់ឌុលឡោះហ្វ៍صلوات الله عليه والسلامដែលមានវចនៈអំពីព្រះបន្ទូលអល់ឡោះហ្វ៍جل *[២:១៩៨] ពុំមានបាបលើពួកអ្នកទេបើពួកអ្នកស្វែងរកព្រះករុណាប្រណីពីព្រះម្ចាស់ពួកអ្នក* ថា៖ «មានន័យថាគ្រឿងទ្រទ្រង់ជីវិត ។ គេអនុញ្ញាតឲ្យបុគ្គលណាដែលបានរួចពីអ៊ិះហ្ររ៉មហើយ ដែលបានធ្វើគ្រប់ពិធីហើយ អាចជួញដូរបានក្នុងរដូវនេះ ។» (262 / 96 : 1 تفسير العيّاشي)

***

أَبُو عَلِيٍّ الطَّبْرِسِيُّ: قِيلَ:كَانُوا يَتَأَثَّمُونَ بِالتِّجَارَةِ فِي الْحَجِّ، فَرَفَعَ اللَّهُ سُبْحَانَهُ بِهَذِهِ اللَّفْظَةِ [الْإِثْمَ] عَمَّنْ يَتَّجِرُ فِي الْحَجِّ» وَ فِي هَذَا تَصْرِيحٌ بِالْإِذْنِ فِي التِّجَارَةِ، قَالَ: وَ هُوَ الْمَرْوِيُّ عَنْ أَئِمَّتِنَا (عَلَيْهِمُ السَّلاَمُ).

អាប៊ូ អាលី អាល់-ត៍ាបារស៊ីបានថ្លែងថា៖ «គេបានតំណាលថា៖ "គេតែងតែថាមានបាបបើធ្វើជំនួញក្នុងពេលធ្វើពិធីហាជ្ជ ។ តែអល់ឡោះហ្វ៍ សូមថ្វាយសេចក្ដីរុងរឿងចំពោះព្រះអង្គجل បានលើក[បម្រាម]នេះចោលដោយព្រះបន្ទូល "បាប" ពាក់ព័ន្ធនឹងបុគ្គលដែលជួញដូរក្នុងពេលបំពេញពិធីហាជ្ជ ។" នេះគឺសេចក្ដីរាយការណ៍មកពីអ៊ីម៉ាំعليهم السلامយើង ។»

وَ قَالَ: وَ قِيلَ: مَعْنَاهُ لاَ جُنَاحَ عَلَيْكُمْ أَنْ تَطْلُبُوا الْمَغْفِرَةَ مِنْ رَبِّكُمْ. قَالَ:وَ رَوَاهُ جَابِرٌ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ). (مجمع البيان 2:527)**

លោកបានថ្លែងថា៖ «គេបានឲ្យដឹងថា៖ "នេះគឺមានន័យថាពុំមានទោសលើអស់លោកទេ អស់លោកគប្បីព្យាយាមសូមខមាទោសពីព្រះម្ចាស់جلរបស់អស់លោក ។"» លោកបានថ្លែងថា៖ «យ៉ាប៉ៀរបានធ្វើសេចក្ដីរាយការណ៍តមកពីអាប៊ូ យ៉ាក់ហ្វារصلوات الله عليه والسلام ។ (527 : 2 مجمع البيان)

***

قَالَ الْإِمَامُ عَلَيْهِ السَّلاَمُ: قَالَ اللَّهُ عَزَّ وَ جَلَّ لِلْحَاجِّ:« فَإِذا أَفَضْتُمْ مِنْ عَرَفاتٍ » وَ مَضَيْتُمْ إِلَى الْمُزْدَلِفَةِ « فَاذْكُرُوا اللَّهَ عِنْدَ الْمَشْعَرِ الْحَرامِ » بِآلاَئِهِ وَ نَعْمَائِهِ، وَ الصَّلاَةِ عَلَى مُحَمَّدٍ سَيِّدِ أَنْبِيَائِهِ، وَ عَلَى عَلِيٍّ سَيِّدِ أَصْفِيَائِهِ، وَ اُذْكُرُوا اللَّهَ « كَما هَداكُمْ » لِدِينِهِ وَ الْإِيمَانِ بِرَسُولِهِ

« وَ إِنْ كُنْتُمْ مِنْ قَبْلِهِ لَمِنَ اَلضَّالِّينَ » عَنْ دِينِهِ مِنْ قَبْلِ أَنْ يَهْدِيَكُمْ إِلَى دِينِهِ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 605)

អ៊ីមុាំ(صلوات الله عليه والسلام) (គឺអ៊ីមុាំហ្ជាសាន់ អាល់-អាស់ការី(صلوات الله عليه والسلام)) មានវចនៈថាៈ «អល់ឡោះហ្ស៊ីមានព្រះបន្ទូលចំពោះបណ្ដាអ្នកធ្វើពិធីហ្ជាជ្ជថាៈ *[២:១៩៨] ពេលពួកអ្នកចាកចេញពីអ្ការ៉ហ្ជាត់* គឺចាកចេញទៅកាន់មុ្ងដ្ទាលីហ្ជាស៊ុ *ចូរពួកអ្នករលឹកដល់អល់ឡោះហ្ស៊ីក្បែរបូជនីយស្ថាន* ដោយព្រះសញ្ញាទាំងឡាយរបស់ព្រះអង្គ(عز وجل)និងព្រះគុណ ហើយចូរឧទ្ទិសសេចក្ដីគោរពចំពោះមូហ្ចាំម៉ាដ(صلى الله عليه وآله) ព្រះអគ្គមហាប្រមុខរបស់ព្រះសាស្ដាទាំងឡាយ(عليهم السلام) និងចំពោះអ្ការ៉ាលី(صلوات الله عليه والسلام) ព្រះអគ្គមហាប្រមុខរបស់ព្រះឧត្ដរាធិការីទាំងឡាយ(عليهم السلام) (គឺស្ដ្ងឡ្ការ៉ាតឲ្យណាប៊ី(صلى الله عليه وآله)និងអាស់លុល-ប៊ែត(عليهم السلام)) ។ *ចូរពួកអ្នករលឹកដល់ព្រះអង្គដែលព្រះអង្គបានដឹកនាំពួកអ្នក* ទៅរកសាសនាព្រះអង្គ(عز وجل) ឲ្យជឿព្រះសាស្ដា(صلى الله عليه وآله)ព្រះអង្គ(عز وجل) *ទ្ធីបើកាលពីមុននោះពួកអ្នកជាជនវង្វេង* ចេញពីសាសនាអល់ឡោះហ្ស៊ី(عز وجل)មុនអល់ឡោះហ្ស៊ី(عز وجل)បានដឹកនាំពួកអ្នកទៅរកសាសនាអល់ឡោះហ្ស៊ី(عز وجل)នោះ ។» ((التفسير الإمام العسكري (عليه السلام) ខណ្ឌ 358)

ثُمَّ أَفِيضُواْ مِنۡ حَيۡثُ أَفَاضَ ٱلنَّاسُ وَٱسۡتَغۡفِرُواْ ٱللَّهَۚ إِنَّ ٱللَّهَ غَفُورٞ رَّحِيمٞ ١٩٩

១៩៩. ក្រោយពីនោះចូរពួកអ្នកចាកចេញ (ចេញពីវាលអ្ការ៉ហ្ជាត់) ពីកន្លែងណាដែលមនុស្សចាកចេញ ចូរពួកអ្នកសូមខមាទោសចំពោះអល់ឡោះហ្ស៊ី ។ អល់ឡោះហ្ស៊ីទ្រង់អត់ឱនទោស ព្រះអង្គមានព្រះមេត្ដាករុណាប្រណី ។

អធិប្បាយអាយ៉ាស៊ុ ១៩៩

« ثُمَّ أَفِيضُوا مِنْ حَيْثُ أَفَاضَ اَلنَّاسُ » اِرْجِعُوا مِنَ اَلْمَشْعَرِ اَلْحَرَامِ مِنْ حَيْثُ رَجَعَ اَلنَّاسُ مِنْ «جَمْعٍ» وَ اَلنَّاسُ هَاهُنَا فِي هَذَا اَلْمَوْضِعِ اَلْحَاجُّ غَيْرُ اَلْحُمْسِ فَإِنَّ اَلْحُمْسَ كَانُوا لاَ يُفِيضُونَ مِنْ جَمْعٍ. « وَ اِسْتَغْفِرُوا اَللَّهَ » لِذُنُوبِكُمْ « إِنَّ اَللَّهَ غَفُورٌ رَحِيمٌ » لِلتَّائِبِينَ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 605)

[២:១៩៩] ចូរពួកអ្នកចាកចេញពីកន្លែងណាដែលមនុស្សចាកចេញ ត្រឡប់ពីបូជនីយស្ថានពិសិដ្ឋតាមកន្លែងណាដែលមនុស្សចាកចេញ "ទាំងអស់គ្នា" ។ ត្រង់នេះ "មនុស្ស" មានន័យថាបណ្ដាអ្នកធ្វើពិធីហ្ជាជ្ជ ដាច់ឡែកពីពួកអាល់-ហ្ជាម៉ាស់ព្រោះពួកនេះមិនចាកចេញពីមុ្ងដ្ទាលីហ្ជាស៊ុទេ *ចូរពួកអ្នកសូមខមាទោសចំពោះអល់ឡោះហ្ស៊ី* ដែលពួកអ្នកបានសាងបាប ។ *អល់ឡោះហ្ស៊ីទ្រង់អត់ឱនទោស ព្រះអង្គមានព្រះមេត្ដាករុណាប្រណី* អល់ឡោះហ្ស៊ី(عز وجل)ទទួលការភ្ជាក់រលឹកស្ដាយក្រោយរាងចាលរបស់ពួកអ្នក ។
((التفسير الإمام العسكري (عليه السلام) ខណ្ឌ 358)

***

ابْنُ مَحْبُوبٍ عَنْ عَبْدِ اللَّهِ بْنِ غَالِبٍ عَنْ أَبِيهِ عَنْ سَعِيدِ بْنِ الْمُسَيَّبِ قَالَ سَمِعْتُ عَلِيَّ بْنَ الْحُسَيْنِ (عليه السلام) يَقُولُ إِنَّ رَجُلًا جَاءَ إِلَى أَمِيرِ الْمُؤْمِنِينَ (عليه السلام) فَقَالَ أَخْبِرْنِي إِنْ كُنْتَ عَالِماً عَنِ النَّاسِ وَ عَنْ أَشْبَاهِ النَّاسِ وَ عَنِ النَّسْنَاسِ فَقَالَ أَمِيرُ الْمُؤْمِنِينَ (عليه السلام) يَا حُسَيْنُ أَجِبِ الرَّجُلَ فَقَالَ الْحُسَيْنُ (عليه السلام) أَمَّا قَوْلُكَ أَخْبِرْنِي عَنِ النَّاسِ فَنَحْنُ النَّاسُ وَ لِذَلِكَ قَالَ اللَّهُ تَعَالَى ذِكْرُهُ فِي كِتَابِهِ ثُمَّ أَفِيضُوا مِنْ حَيْثُ أَفَاضَ النَّاسُ فَرَسُولُ اللَّهِ (صلى الله عليه وآله) الَّذِي أَفَاضَ بِالنَّاسِ

អ៊ីបនូ ម៉ាស៊្សប៊ុប បានតំណាលតមកពីអាប៊ូឌ្ខុលឡោះហ៊្វ ប៊ិន ក៏លិប តមកពីឪពុកលោក សាអ៊ីដូ ប៊ិន អាល់-មូសៃយ៉ាប់ដែលបានតំណាលថា ខ្ញុំបានឮ អាលី صلوات الله عليه والسلام ប៊ិន អាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام មានវចនៈថា បុរសម្នាក់បានមកជួបអាមីរុល-មុមីនីន صلوات الله عليه والسلام ទូលព្រះអង្គ صلوات الله عليه والسلام ថា៖ "សូមព្រះអង្គ صلوات الله عليه والسلام ប្រាប់ទូលបង្គំឲ្យបានដឹងផងថា តើព្រះអង្គ صلوات الله عليه والسلام ស្គាល់មនុស្សទេ ស្គាល់អ្នកដែលដូចមនុស្សទេ និងស្គាល់*អាល់-ណាស់ណាស់* (النَّسْنَاسِ) ទេ ។" អាមីរុល-មុមីនីន صلوات الله عليه والسلام មានវចនៈថា៖ "ហ៊្វូសៃន៍ صلوات الله عليه والسلام អើយ ចូរឆ្លើយគាត់ទៅ ។" អាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام មានវចនៈថា៖ "សម្ដីលោកដែលថា៖ "សូមប្រាប់ទូលបង្គំឲ្យដឹងអំពីមនុស្ស" នោះ យើង عليهم السلام ជាមនុស្ស ហើយនេះគឺអ្វីដែលអល់ឡោះហ៊្វ عز وجل មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរព្រះអង្គ عز وجل ថា៖ *[២:១៩៩] ក្រោយពីនោះចូរពួកអ្នកចាកចេញពីកន្លែងណាដែលមនុស្សចាកចេញ* ដូច្នេះនេះគឺរ៉ស៊ូលុលឡោះហ៊្វ صلى الله عليه وآله وسلم ព្រះអង្គ صلى الله عليه وآله وسلم គឺបុគ្គលដែលមនុស្សត្រូវតែមករក ។

وَ أَمَّا قَوْلُكَ أَشْبَاهُ النَّاسِ فَهُمْ شِيعَتُنَا وَ هُمْ مَوَالِينَا وَ هُمْ مِنَّا وَ لِذَلِكَ قَالَ إِبْرَاهِيمُ (عليه السلام) فَمَنْ تَبِعَنِي فَإِنَّهُ مِنِّي وَ أَمَّا قَوْلُكَ النَّسْنَاسُ فَهُمُ السَّوَادُ الْأَعْظَمُ وَ أَشَارَ بِيَدِهِ إِلَى جَمَاعَةِ النَّاسِ ثُمَّ قَالَ إِنْ هُمْ إِلَّا كَالْأَنْعامِ بَلْ هُمْ أَضَلُّ سَبِيلًا .

សម្ដីលោកដែលថា៖ "ដូចមនុស្ស" នោះ ពួកគេគឺស៊ីអាស់យើង عليهم السلام ពួកគេជាមិត្តយើង عليهم السلام ពួកគេជាគ្នាយើង عليهم السلام ហើយនេះគឺអ្វីដែលអ៊ីបរ៉ហ៊ីម عليه السلام បានថា គឺ៖ *[១៤:៣៦] អ្នកណាតាមទូលព្រះបង្គំជាខ្ញុំ អ្នកនោះជាគ្នារបស់ទូលព្រះបង្គំជាខ្ញុំ រីឯអ្នកណាមិនស្ដាប់បង្គាប់ទូលព្រះបង្គំជាខ្ញុំទេ ។* សម្ដីលោកដែលថា៖ *"អាល់-ណាស់ណាស់"* នោះ ពួកគេគឺភាគច្រើនជាងគេ" ព្រះអង្គ صلوات الله عليه والسلام ចង្អុលទៅរកមនុស្សមួយក្រុម ហើយមានវចនៈថា៖ *[២៥:៤៤] អ្នកស្មានថាពួកគេភាគច្រើនឮឬចេះត្រិះរិះឬ ? ពួកគេមិនដូចអ្វីក្រៅពីដូចសត្វទេ ។ ពួកគេវង្វេងលើសនោះទៅទៀតពីមាគ៌ា ។"* (الكافي 8: 245/ 39) 14:32-36, 25:44

***

مُحَمَّدُ بْنُ يَعْقُوبَ: عَنْ عَلِيِّ بْنِ إِبْرَاهِيمَ، عَنْ أَبِيهِ، وَ مُحَمَّدِ بْنِ إِسْمَاعِيلَ، عَنِ الْفَضْلِ بْنِ شَاذَانَ، جَمِيعاً، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ مُعَاوِيَةَ بْنِ عَمَّارٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «إِنَّ رَسُولَ اللَّهِ(صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) - وَ ذَكَرَ (عَلَيْهِ السَّلاَمُ) حَجَّ النَّبِيِّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)، إِلَى أَنْ قَالَ -: وَ كَانَتْ قُرَيْشٌ تُفِيضُ مِنَ الْمُزْدَلِفَةِ وَ هِيَ جَمْعٌ، وَ يَمْنَعُونَ النَّاسَ أَنْ يُفِيضُوا مِنْهَا، فَأَقْبَلَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ)، وَ قُرَيْشٌ تَرْجُو أَنْ تَكُونَ إِفَاضَتُهُ مِنْ حَيْثُ كَانُوا يُفِيضُونَ، فَأَنْزَلَ اللَّهُ عَزَّ وَ جَلَّ عَلَيْهِ: "ثُمَّ أَفِيضُوا مِنْ حَيْثُ أَفاضَ النَّاسُ وَ اسْتَغْفِرُوا اللَّهَ" يَعْنِي إِبْرَاهِيمَ وَ إِسْمَاعِيلَ وَ إِسْحَاقَ فِي إِفَاضَتِهِمْ مِنْهَا، وَ مَنْ كَانَ بَعْدَهُمْ». (الكافي 247/ 4: 4)**

[...] មូអាវីយ៉ាស់ ប៊ិន អាម៉ារបានតំណាលតមកពីអាប៊ូ អាប់ឌុលឡោះហ៊្វ صلوات الله عليه والسلام ដែលមានវចនៈថា៖ «រ៉ស៊ូលុលឡោះហ៊្វ صلى الله عليه وآله وسلم ។» ព្រះអង្គ صلوات الله عليه والسلام ក៏បានថ្លែងអំពីពិធីហាច្ជរបស់ព្រះសាស្ដា صلى الله عليه وآله وسلم លុះដល់៖ «ពួកគូរ៉យ់ស្ហ៍មួយក្រុមបានចាកចេញពីមុស្ដាលីហ្វាស់ ហើយមិនឲ្យមនុស្សចាកចេញទៅជាមួយពួកគេទេ ។ ពេលរ៉ស៊ូលុលឡោះហ៊្វ صلى الله عليه وآله وسلم មកដល់ ពួកគូរ៉យ់ស្ហ៍សង្ឃឹមថាព្រះអង្គ صلى الله عليه وآله وسلم នឹងមកតាមកន្លែងដែលពួកគេបានចេញមកនោះដែរ ។ ដូច្នេះអល់ឡោះហ៊្វ عز وجل បានបើកឲ្យដឹងថា៖ *[២:១៩៩] ក្រោយពីនោះចូរពួកអ្នកចាកចេញពីកន្លែងណាដែលមនុស្សចាកចេញ ចូរពួកអ្នកសូមខមាទោសចំពោះអល់ឡោះហ៊្វ* មានន័យថាការចាកចេញពីកន្លែងរបស់អ៊ីបរ៉ហ៊ីម عليه السلام អ៊ីសម៉ាអ៊ីល عليه السلام អ៊ីសហាក់ عليه السلام និងបណ្ដាអ្នកក្រោយពីព្រះអង្គទាំងបីអង្គនេះ عليهم السلام ។» (الكافي 4 : 247 / 4)

***

عَنْ أَبِي الصَّبَّاحِ، عَنْ أَبِي عَبْدِ اللهِ (عَلَيْهِ السَّلاَمُ)، قَالَ: «إِنَّ إِبْرَاهِيمَ أَخْرَجَ إِسْمَاعِيلَ إِلَى الْمَوْقِفِ فَأَفَاضَا مِنْهُ، ثُمَّ إِنَّ النَّاسَ كَانُوا يُفِيضُونَ مِنْهُ، حَتَّى إِذَا كَثُرَتْ قُرَيْشٌ، قَالُوا: لاَ نُفِيضُ مِنْ حَيْثُ أَفَاضَ النَّاسُ، وَ كَانَتْ قُرَيْشٌ تُفِيضُ مِنَ الْمُزْدَلِفَةِ، وَ مَنَعُوا النَّاسَ أَنْ يُفِيضُوا مَعَهُمْ إِلاَّ مِنْ عَرَفَاتٍ، فَلَمَّا بَعَثَ اللهُ مُحَمَّداً (صَلَّى اللهُ عَلَيْهِ وَ آلِهِ) أَمَرَهُ أَنْ يُفِيضَ مِنْ حَيْثُ أَفَاضَ النَّاسُ، وَ عَنَى بِذَلِكَ إِبْرَاهِيمَ وَ إِسْمَاعِيلَ (عَلَيْهِمَا السَّلاَمُ)». (تفسير العيّاشي 97 /268 :1)**

អាប៊ូ អាល់-ស្ហ៍បាស្ហ៍បានតំណាលតមកពីអាប៊ូ អាប់ឌុលឡោះហ្ ﷺ ដែលមានវចនៈថា៖ «អ៊ីបរ៉ហ៊ីម ؑ នាំអ៊ីសម៉ាអ៊ីល ؑ មកកន្លែងឈប់ហើយបានចាកចេញពីទីនោះ ។ ក្រោយមកមនុស្សតែងតែចាកចេញពីទីនោះ ទាល់តែពួកគូរ៉យ៉ស្ហ៍មានចំនួនច្រើនឡើង ។ ពួកគេថា៖ "ចូរកុំចាកចេញពេលមនុស្សចាកចេញ ។" ពួកគូរ៉យ៉ស្ហ៍តែងតែចាកចេញពីអាល់-មុស្ទាលីហ្វាស្ហ៍ហើយមិនឲ្យមនុស្សចាកចេញទៅជាមួយពួកគេទេ លើកលែងតែពីអារ៉ហ្វាត់ ។ ពេលអល់ឡោះហ្ ﷻ បានបញ្ជូនមូហាំម៉ាដ់ ﷺ មក ព្រះអង្គ ﷻ បានបញ្ជាឲ្យមូហាំម៉ាដ់ ﷺ ចាកចេញពីកន្លែងដែលមនុស្សចាកចេញ មានន័យថាអ៊ីបរ៉ហ៊ីម ؑ និងអ៊ីសម៉ាអ៊ីល ؑ (គឺចាកចេញតាមកន្លែងដែលអ៊ីបរ៉ហ៊ីម ؑ និងអ៊ីសម៉ាអ៊ីល ؑ បានចាកចេញ) ។»
(تفسير العيّاشي 1: 97/ 268)

فَإِذَا قَضَيْتُم مَّنَٰسِكَكُمْ فَٱذْكُرُوا۟ ٱللَّهَ كَذِكْرِكُمْ ءَابَآءَكُمْ أَوْ أَشَدَّ ذِكْرًا ۗ فَمِنَ ٱلنَّاسِ مَن يَقُولُ رَبَّنَآ ءَاتِنَا فِى ٱلدُّنْيَا وَمَا لَهُۥ فِى ٱلْءَاخِرَةِ مِنْ خَلَٰقٍ ﴿٢٠٠﴾

២០០. ពេលពួកអ្នកបានធ្វើរួចស្រេចពិធីទាំងឡាយហើយ ចូរពួកអ្នករលឹកដល់អល់ឡោះហ្ ដូចពួកអ្នករលឹកដល់ដូនតាពួកអ្នក ឬរលឹកខ្លាំងជាងនោះ ។ ពួកគេខ្លះថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គមេត្តាប្រោសប្រទានឲ្យពួកទូលព្រះបង្គំជាខ្ញុំក្នុងលោកនេះ ។" អ្នកនោះនឹងពុំបានចំណែកលោកមុខទេ ។

وَمِنْهُم مَّن يَقُولُ رَبَّنَآ ءَاتِنَا فِى ٱلدُّنْيَا حَسَنَةً وَفِى ٱلْءَاخِرَةِ حَسَنَةً وَقِنَا عَذَابَ ٱلنَّارِ ﴿٢٠١﴾

២០១. ពួកគេខ្លះថា៖ "ព្រះម្ចាស់អើយ សូមអង្គព្រះមេត្តាប្រទានឲ្យពួកទូលព្រះបង្គំជាខ្ញុំនូវអ្វីៗដែលល្អប្រសើរក្នុងលោកនេះ អ្វីៗដែលល្អប្រសើរក្នុងលោកមុខ ។ សូមព្រះអង្គមេត្តាស្រោចស្រង់ពួកទូលបង្គំជាខ្ញុំឲ្យផុតពីទណ្ឌកម្មភ្លើងនរកផង ។"

أُو۟لَٰٓئِكَ لَهُمْ نَصِيبٌ مِّمَّا كَسَبُوا۟ ۚ وَٱللَّهُ سَرِيعُ ٱلْحِسَابِ ﴿٢٠٢﴾

២០២. ពួកទាំងនោះនឹងបានចំណែកនៃអំពើដែលពួកគេបានសាង ។ អល់ឡោះហ្ទូទាត់យ៉ាងឆាប់រហ័ស ។

អធិប្បាយអាយ៉ាស្ហ៍ ២០០-២០២

« فَإِذٰا قَضَيْتُمْ مَنٰاسِكَكُمْ » اَلَّتِي سُنَّتْ لَكُمْ فِي حَجِّكُمْ « فَاذْكُرُوا اَللّٰهَ كَذِكْرِكُمْ آبٰاءَكُمْ » اُذْكُرُوا اَللّٰهَ بِآلاٰئِهِ لَدَيْكُمْ وَ إِحْسَانِهِ إِلَيْكُمْ فِيمَا

وَفَّقَكُمْ لَهُ مِنَ اَلْإِيمَانِ بِنُبُوَّةِ مُحَمَّدٍ صَلَّى اللهُ عَلَيْهِ وَ آلِهِ سَيِّدِ اَلْأَنَامِ وَ اِعْتِقَادِ وَصِيِّهِ أَخِيهِ عَلِيٍّ زَيْنِ أَهْلِ اَلْإِسْلاَمِ كَذِكْرِكُمْ آبَاءَكُمْ بِأَفْعَالِهِمْ وَ مَآثِرِهِمُ الَّتِي تَذْكُرُونَهَا « أَوْ أَشَدَّ ذِكْراً » خَيَّرَهُمْ بَيْنَ ذَلِكَ وَ لَمْ يُلْزِمْهُمْ أَنْ يَكُونُوا لَهُ أَشَدَّ ذِكْراً مِنْهُمْ لِآبَائِهِمْ وَ إِنْ كَانَتْ نِعَمُ اَللَّهِ عَلَيْهِمْ أَكْثَرَ وَ أَعْظَمَ مِنْ نِعَمِ آبَائِهِمْ.

អ៊ីមុាំ (គឺអ៊ីមុាំអាល់-ហ្ជាសាន់ អាល់-អ្ហ្ការីសូ) មានវចនៈថា៖ *«[២:២០០] ពេលពួកអ្នកបានធ្វើរួចស្រេចពិធីទាំងឡាយហើយ* ដែលបានបញ្ញត្តិមកសម្រាប់ធ្វើពិធីហ្ជាជ *ចូរពួកអ្នករលឹកដល់អល់ឡោះហ្ជ៍ ដូចពួកអ្នករលឹកដល់ដូនតាពួកអ្នក* ចូរពួកអ្នកនឹករលឹកដល់អល់ឡោះ(ﷻ)ដែលបានប្រសិទ្ធពរជ័យដល់ពួកអ្នក ដែលបានប្រោសប្រណីពួកអ្នកដោយធ្វើឲ្យពួកអ្នកទន់ទេរទៅរកជំនឿលើសាស្តាភាពរបស់មូហ្ហាំម៉ាដ(ﷺ) ព្រះអគ្គមហាប្រមុខរបស់សត្វលោកទាំងឡាយ ទេរទៅរកជំនឿលើព្រះឧត្តរាធិការី(عليه السلام)របស់គេ(ﷺ) គឺអ្ហ្លី(عليه السلام) ប្អូនរបស់គេ(ﷺ)ដែលជាសម្រស់របស់ប្រជានិករអ៊ីស្លាម ដូចពួកអ្នកនឹករលឹកដល់ដូនតាពួកអ្នកដែរ គឺនឹកនាដល់ទង្វើនឹងអនុស្សាវរីយ៍របស់ពួកគេ *ឬរលឹកខ្លាំងជាងនោះ* នេះជាប្រការប្រសើរបំផុតសម្រាប់ពួកគេ ។ ពួកគេមិនចាំបាច់នឹករលឹកអល់ឡោះ(ﷻ)ខ្លាំងជាងនឹករលឹកដូនតាពួកគេទេ ទោះបីព្រះគុណរបស់អល់ឡោះ(ﷻ)មកលើពួកគេនោះច្រើនជាងនិងធំធេងជាងគុណដូនតាពួកគេនោះក៏ដោយ ។

ثُمَّ قَالَ [اَللَّهُ] عَزَّ وَ جَلَّ « فَمِنَ اَلنَّاسِ مَنْ يَقُولُ رَبَّنَا آتِنَا فِي اَلدُّنْيَا » أَمْوَالَهَا وَ خَيْرَاتِهَا « وَ مَا لَهُ فِي اَلْآخِرَةِ مِنْ خَلاَقٍ » نَصِيبٍ لِأَنَّهُ لاَ يَعْمَلُ لَهَا عَمَلاً وَ لاَ يَطْلُبُ فِيهَا خَيْراً.

អល់ឡោះ(ﷻ)មានព្រះបន្ទូលថា៖ *[២:២០០] ពួកគេខ្លះថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គមេត្តាប្រោសប្រទានឲ្យពួកទូលព្រះបង្គំជាខ្ញុំក្នុងលោកនេះ"* គឺទ្រព្យនិងអ្វីៗដែលល្អប្រសើរ *អ្នកនោះនឹងពុំបានចំណែកលោកមុខទេ* គឺមួយចំណែក ព្រោះអ្នកនោះមិនបានប្រព្រឹត្តទង្វើណាមមួយដើម្បីលោកមុខនោះទេ មិនព្យាយាមស្វែងរកសេចក្តីល្អណាមួយដើម្បីលោកមុខនោះទេ ។

« وَ مِنْهُمْ مَنْ يَقُولُ رَبَّنَا آتِنَا فِي اَلدُّنْيَا حَسَنَةً » خَيْرَاتِهَا « وَ فِي اَلْآخِرَةِ حَسَنَةً » مِنْ نِعَمِ جَنَّاتِهَا « وَ قِنَا عَذَابَ اَلنَّارِ » نَجِّنَا مِنْ عَذَابِ اَلنَّارِ وَ هُمْ بِاللهِ مُؤْمِنُونَ، وَ بِطَاعَتِهِ عَامِلُونَ وَ لِمَعَاصِيهِ مُجَانِبُونَ، « أُولَئِكَ » اَلدَّاعُونَ بِهَذَا اَلدُّعَاءِ عَلَى هَذَا اَلْوَصْفِ « لَهُمْ نَصِيبٌ مِمَّا كَسَبُوا » مِنْ ثَوَابِ مَا كَسَبُوا فِي اَلدُّنْيَا وَ فِي اَلْآخِرَةِ.

[២:២០១] ពួកគេខ្លះថា៖ "ព្រះម្ចាស់អើយ សូមអង្គព្រះមេត្តាប្រទានឲ្យពួកទូលព្រះបង្គំជាខ្ញុំនូវអ្វីៗដែលល្អប្រសើរក្នុងលោកនេះនិង ធនធានល្អប្រសើរក្នុងលោកនេះ *អ្វីៗដែលល្អប្រសើរក្នុងលោកមុខ* អំណោយនៃសួនសួគ៌ ។ *សូមព្រះអង្គមេត្តាស្រោចស្រង់ពួកទូលបង្គំជាខ្ញុំឲ្យផុតពីទណ្ឌកម្មភ្លើងនរកផង"* សូមព្រះអង្គ(ﷻ)ជួយអស់ទូលព្រះបង្គំជាខ្ញុំឲ្យផុតពីទណ្ឌកម្មភ្លើងនរក សូមស្បថចំពោះ អល់ឡោះ(ﷻ) ពួកគេគឺមុមីន (អ្នកមានសទ្ធាជ្រះថ្លា) ដែលស្តាប់បង្គាប់អល់ឡោះ(ﷻ) ដែលចៀសវាងល្មើសបង្គាប់ព្រះអង្គ(ﷻ) ។ *[២:២០២] ពួកទាំងនោះ* គឺបណ្តាអ្នកដែលបួងសួងបែបនេះ *នឹងបានចំណែកនៃអំពើដែលពួកគេបានសាង* គឺរង្វាន់ដែលពួកគេបាននៅក្នុងលោកនេះនិងក្នុងលោកមុខ ។

« وَ اَللهُ سَرِيعُ اَلْحِسَابِ » لِأَنَّهُ لاَ يَشْغَلُهُ شَأْنٌ عَنْ شَأْنٍ، وَ لاَ مُحَاسَبَةُ أَحَدٍ مِنْ مُحَاسَبَةِ آخَرَ، فَإِذَا حَاسَبَ وَاحِداً فَهُوَ فِي تِلْكَ اَلْحَالِ

مُحَاسِبٌ لِلْكُلِّ، يُتِمُّ حِسَابَ اَلْكُلَّ بِتَمَامِ حِسَابِ وَاحِدٍ، وَ هُوَ كَقَوْلِهِ « مَا خَلْقُكُمْ وَ لاَ بَعْثُكُمْ إِلاَّ كَنَفْسٍ وَاحِدَةٍ » لاَ يَشْغَلُهُ خَلْقُ وَاحِدٍ عَنْ خَلْقِ آخَرَ [وَ لاَ بَعْثُ وَاحِدٍ عَنْ بَعْثِ آخَرَ].

អល់ឡោះហ្វ៉ាទូទាត់យ៉ាងឆាប់រហ័ស អល់ឡោះហ្ស៊ីវ៉ាជ្ជ៉ាមិនជាប់រវល់តែជាមួយរឿងអ្នកណាមួយដោយមិនរវល់អំពីអ្នកឯទៀតឡើយ ព្រះអង្គ ﷻ មិនជាប់រវល់តែទូទាត់អ្នកណាមួយដោយមិនរវល់ទូទាត់អ្នកឯទៀតឡើយ ។ ពេលព្រះអង្គ ﷻ ទូទាត់អ្នកណាមួយ ក្នុងពេលតែមួយនេះព្រះអង្គ ﷻ ទូទាត់អ្នកឯទៀតគ្រប់គ្នាដែរ ។ ព្រះអង្គ ﷻ ទូទាត់អ្នកទាំងអស់គ្នាចប់សព្វគ្រប់ក្នុងពេលដែលព្រះអង្គ ﷻ បានទូទាត់បុគ្គលម្នាក់ចប់ ដូចព្រះអង្គ ﷻ មានព្រះបន្ទូលថា៖ *[៣១:២៨] ការបង្កើតពួកអ្នកនិងការធ្វើឲ្យពួកអ្នករស់ពីស្លាប់ឡើងវិញ [សម្រាប់ព្រះអង្គនោះ] គ្រាន់តែជាដូច[ការបង្កើតនិងការធ្វើឲ្យរស់ឡើងវិញរបស់]មនុស្សតែមួយនាក់ប៉ុណ្ណោះ ។* ព្រះអង្គ ﷻ មិនជាប់រវល់តែបង្កើតមនុស្សម្នាក់ដោយមិនរវល់អើពើដល់ការបង្កើតមនុស្សម្នាក់ទៀតឡើយ ។ ព្រះអង្គ ﷻ មិនជាប់រវល់តែធ្វើឲ្យមនុស្សម្នាក់រស់ឡើងវិញដោយមិនរវល់អើពើដល់ការធ្វើឲ្យមនុស្សម្នាក់ទៀតរស់ឡើងវិញឡើយ ។

قَالَ عَلِيُّ بْنُ اَلْحُسَيْنِ عَلَيْهِمَا السَّلاَمُ وَ هُوَ وَاقِفٌ بِعَرَفَاتٍ لِلزُّهْرِيِّ: كَمْ تُقَدِّرُ هَاهُنَا مِنَ اَلنَّاسِ؟ قَالَ: أُقَدِّرُ أَرْبَعَةَ آلاَفِ أَلْفٍ وَ خَمْسَمِائَةِ أَلْفٍ كُلُّهُمْ حُجَّاجٌ قَصَدُوا اَللَّهَ بِآمَالِهِمْ وَ يَدْعُونَهُ بِضَجِيجِ أَصْوَاتِهِمْ.

អ៊ីម៉ាំអ្ហ្ម៉ាលី ﷺ ប៊ិន អាល់-ហ្ស៊ីសែន ﷺ បានសួរស៊ីស៊ូសរី កាលព្រះអង្គ ﷺ នៅឯអ្ហ៊ារ៉ាហ្ជាត់ ថា៖ "លោកស្មានបានទេថាតើមានមនុស្សប៉ុន្មាននាក់នៅទីនេះ ?" លោកបានតបថា៖ "ទូលបង្គំគិតថាមានប្រមាណបួនឬប្រាំរយពាន់នាក់ ។ អ្នកធ្វើពិធីហ្ហាជ្ជ ទាំងអស់សុទ្ធតែលះបង់ទ្រព្យលើមាគ៌ាអល់ឡោះហ្ស៊ីវ៉ាជ្ជ ﷻ បួងសួងអល់ឡោះហ្ស៊ីវ៉ាជ្ជ ﷻ ឡូងៗ ។"

[فَقَالَ لَهُ: يَا زُهْرِيُّ مَا أَكْثَرَ اَلضَّجِيجَ وَ أَقَلَّ اَلْحَجِيجَ! فَقَالَ اَلزُّهْرِيُّ: كُلُّهُمْ حُجَّاجٌ، أَ فَهُمْ قَلِيلٌ؟]. فَقَالَ لَهُ: يَا زُهْرِيُّ أَدْنِ لِي وَجْهَكَ. فَأَدْنَاهُ إِلَيْهِ، فَمَسَحَ بِيَدِهِ وَجْهَهُ، ثُمَّ قَالَ: اُنْظُرْ. [فَنَظَرَ] إِلَى اَلنَّاسِ، قَالَ اَلزُّهْرِيُّ: فَرَأَيْتُ أُولَئِكَ اَلْخَلْقَ كُلَّهُمْ قِرَدَةً، لاَ أَرَى فِيهِمْ إِنْسَاناً إِلاَّ فِي كُلِّ عَشَرَةِ آلاَفٍ وَاحِداً مِنَ اَلنَّاسِ.

ព្រះអង្គ ﷺ បានប្រាប់លោកថា៖ "ស៊ីស៊ូសរីអើយ ច្រើនតែការបួងសួងទេ តែអ្នកបួងសួងមានចំនួនតិច ។" ស៊ីស៊ូសរីបានទូលថា៖ "ពួកគេទាំងអស់គ្នាជាអ្នកធ្វើពិធីហ្ហាជ្ជ ។ ព្រះអង្គ ﷺ ថាពួកគេតិច ?" ព្រះអង្គ ﷺ បានប្រាប់លោកថា៖ "ស៊ីស៊ូសរីអើយ ខិតមុខលោកមកជិតខ្ញុំ ﷺ ។" លោកក៏បានខិតចូលជិត ព្រះអង្គ ﷺ បានយកដៃប៉ះមុខលោកហើយមានវចនៈថា៖ "ចូរលោកមើលទៅ ។" លោកក៏បានមើលទៅមនុស្សទាំងនោះហើយថា៖ "ទូលបង្គំមើលឃើញសត្វលោកទាំងនេះដូចសត្វស្វា ។ ក្នុងចំណោមពួកគេទាំងនោះទូលបង្គំមិនឃើញមានមនុស្សទេ ។ ឃើញមានតែមនុស្សម្នាក់ក្នុងចំណោមពួកគេដប់ពាន់នាក់ ។"

ثُمَّ قَالَ لِيَ: أُدْنُ مِنِّي يَا زُهْرِيُّ. فَدَنَوْتُ مِنْهُ، فَمَسَحَ بِيَدِهِ وَجْهِي ثُمَّ قَالَ: اُنْظُرْ. فَنَظَرْتُ إِلَى اَلنَّاسِ، قَالَ اَلزُّهْرِيُّ: فَرَأَيْتُ أُولَئِكَ اَلْخَلْقَ كُلَّهُمْ [خَنَازِيرَ، ثُمَّ قَالَ لِي: أَدْنِ لِي وَجْهَكَ. فَأَدْنَيْتُ مِنْهُ، فَمَسَحَ بِيَدِهِ وَجْهِي، فَإِذَا هُمْ كُلُّهُمْ] ذِئْبَةٌ إِلاَّ تِلْكَ اَلْخَصَائِصَ مِنَ اَلنَّاسِ نَفَراً يَسِيراً.

បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام បានប្រាប់លោកថា៖ "ស៊ុហ្សរីអើយ ចូលមកជិតខ្ញុំ صلوات الله عليه والسلام ។" លោកក៏បានចូលមកជិត ព្រះអង្គ صلوات الله عليه والسلام បានយកដៃប៉ះមុខលោកហើយមានវចនៈថា៖ "ចូរលោកមើលទៅ ។" លោកក៏មើលទៅឯមនុស្សទាំងនោះហើយថា៖ "ទូលបង្គំមើលឃើញសត្វលោកទាំងនេះដូចជ្រូក ។" បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام បានប្រាប់លោកថា៖ "ស៊ុហ្សរីអើយ ខិតមុខលោកមកជិតខ្ញុំ صلوات الله عليه والسلام ។" លោកក៏បានខិតចូលជិតព្រះអង្គ صلوات الله عليه والسلام បានយកដៃប៉ះមុខលោក ពួកគេទាំងនោះដូចឆ្កែព្រៃ ។ តិចណាស់ដែលមានលក្ខណៈជាមនុស្ស ។

فَقُلْتُ: بِأَبِي وَ أُمِّي يَا اِبْنَ رَسُولِ اَللَّهِ قَدْ أَدْهَشَتْنِي آيَاتُكَ، وَ حَيَّرَتْنِي عَجَائِبُكَ! قَالَ: يَا زُهْرِيُّ مَا اَلْحَجِيجُ مِنْ هَؤُلاَءِ إِلاَّ اَلنَّفَرُ اَلْيَسِيرُ اَلَّذِينَ رَأَيْتَهُمْ بَيْنَ هَذَا اَلْخَلْقِ اَلْجَمِّ اَلْغَفِيرِ. ثُمَّ قَالَ لِي: اِمْسَحْ يَدَكَ عَلَى وَجْهِكَ. فَفَعَلْتُ، فَعَادَ أُولَئِكَ اَلْخَلْقُ فِي عَيْنِي نَاساً كَمَا كَانُوا أَوَّلاً.

ស៊ុហ្សរីបានទូលថា៖ "សូមឲ្យទូលបង្គំបានធ្វើពលីកម្មឪពុកម្ដាយដើម្បីព្រះអង្គ صلوات الله عليه والسلام ព្រះរាជបុត្រ صلوات الله عليه والسلام រ៉សូលុលឡោះហ៍ ﷺ អើយ ហេតុការណ៍អស្ចារ្យរបស់ព្រះអង្គ صلوات الله عليه والسلام ធ្វើឲ្យទូលបង្គំភ្ញាក់ផ្អើលខ្លាំង ទូលបង្គំភាំងស្មារតី !" ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ស៊ុហ្សរីអើយ តិចណាស់ជាអ្នកធ្វើពិធីហាជ្ជក្នុងហ្វូងសន្ធឹកសន្ធាប់ដែលលោកឃើញមាននៅទីនេះ ។" បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ចូរលោកយកដៃជូតមុខទៅ ។" "ខ្ញុំក៏បានធ្វើដូច្នេះ ។ សត្វលោកទាំងនោះក៏បានទៅជាមនុស្សវិញដូចដើម ។

ثُمَّ قَالَ لِي: مَنْ حَجَّ وَ وَالَى مُوَالِيَنَا، وَ هَجَرَ مُعَادِيَنَا، وَ وَطَّنَ نَفْسَهُ عَلَى طَاعَتِنَا، ثُمَّ حَضَرَ هَذَا اَلْمَوْقِفَ مُسَلِّماً إِلَى اَلْحَجَرِ اَلْأَسْوَدِ مَا قَلَّدَهُ اَللَّهُ مِنْ أَمَانَاتِنَا، وَ وَفِيّاً بِمَا أَلْزَمَهُ مِنْ عُهُودِنَا، فَذَلِكَ هُوَ اَلْحَاجُّ، وَ اَلْبَاقُونَ هُمْ مَنْ قَدْ رَأَيْتَهُمْ. (التفسير المنسوب إلى الإمام العسكري عليه السلام , ج 1 , ص 606)

បន្ទាប់ពីនោះព្រះអង្គ صلوات الله عليه والسلام បានប្រាប់ខ្ញុំថា៖ "បុគ្គលដែលធ្វើពិធីហាជ្ជ ដែលជាមិត្តរបស់មិត្តយើង عليهم السلام ដែលចៀសឆ្ងាយពីសត្រូវយើង عليهم السلام ដែលចុះចូលខ្លួនក្រោមបង្គាប់យើង عليهم السلام បន្ទាប់មកបាននៅទីនេះ ហើយបានទៅឯថ្មខ្មៅជាមួយអ៊ីម៉ាម៉ាស់ដែលអល់ឡោះហ៍ ﷻ បានដាក់ជាអំរែកមកលើអ្នកនោះ បានធ្វើតាមកាតព្វកិច្ចដែលពួកគេបានស្បថជាមួយយើង عليهم السلام បុគ្គលនោះជាអ្នកធ្វើពិធីហាជ្ជ ។ តែអ្នកឯទៀត គឺអ្វីដែលលោកបានឃើញនោះឯង ។"» ((التفسير الإمام العسكري (عليه السلام) ខណ្ឌ358-359)

***

عَنْهُ: عِدَّةٌ مِنْ أَصْحَابِنَا، عَنْ أَحْمَدَ بْنِ مُحَمَّدٍ، عَنِ ابْنِ مَحْبُوبٍ، عَنْ جَمِيلِ بْنِ صَالِحٍ، عَنْ أَبِي عَبْدِ اللَّهِ (عليه السلام)، فِي قَوْلِ اللَّهِ عَزَّ وَ جَلَّ: رَبَّنا آتِنا فِي الدُّنْيا حَسَنَةً وَ فِي الْآخِرَةِ حَسَنَةً. قَالَ: «رِضْوَانُ اللَّهِ وَ الْجَنَّةُ فِي الْآخِرَةِ وَ الْمَعَاشُ وَ حُسْنُ الْخُلُقِ فِي الدُّنْيَا».

[...] យ៉ាមីល ប៊ិន ស្វលិះហ្វ៍បានតំណាលតមកពីអាប៊ូ អាប់ឌុលឡោះហ្វ៍ صلوات الله عليه والسلام ដែលមានវចនៈអំពីព្រះបន្ទូលអល់ឡោះហ្វ៍ ﷻ *[២:២០១] ពួកគេខ្លះថា៖ "ព្រះម្ចាស់អើយ សូមអង្គព្រះមេត្តាប្រទានឲ្យពួកទូលព្រះបង្គំជាខ្ញុំនូវអ្វីៗដែលល្អប្រសើរក្នុងលោកនេះ អ្វីៗដែលល្អប្រសើរក្នុងលោកមុខ ។ សូមព្រះអង្គមេត្តាស្រោចស្រង់ពួកទូលបង្គំជាខ្ញុំឲ្យផុតពីទណ្ឌកម្មភ្លើងនរកផង"* ថា៖ «គឺសព្វព្រះហឫទ័យអល់ឡោះហ្វ៍ ﷻ

និង[បានចូល]ឋានសួគ៌ក្នុងលោកមុខ [មាន]ជីវិតរស់នៅនិងសីលធម៌ល្អប្រសើរក្នុងលោកនេះ ។»
(الكافي 5 : 71 / 2)

***

الْعَيَّاشِيُّ: عَنْ مُحَمَّدِ بْنِ مُسْلِمٍ، قَالَ: سَأَلْتُ أَبَا جَعْفَرٍ (عَلَيْهِ السَّلاَمُ) فِي قَوْلِ اللَّهِ: "فَاذْكُرُوا اللهَ كَذِكْرِكُمْ آبَاءَكُمْ أَوْ أَشَدَّ ذِكْراً". قَالَ: «كَانَ الرَّجُلُ فِي الْجَاهِلِيَّةِ يَقُولُ: كَانَ أَبِي، وَ كَانَ أَبِي، فَأُنْزِلَتْ هَذِهِ الْآيَةُ فِي ذَلِكَ». (تفسير العيّاشي 98/ 270: 1)**

